# ដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត

**GOOD NEWS OF JESUS**

**BIBLE STORIES**

# សេចក្តីពិតខាងវិញ្ញាណ

**SPRIRITUAL TRUTHS**

*រៀបរៀងដោយ*

គ្រីស្ទី អេឃីន ប្រនើរ

| | | |
|---|---|---|
| First Printing | 4,000 copies | February 2004 |
| Second Printing | 2,000 copies | September 2009 |
| Third Printing | 2,000 copies | April 2010 |
| Fourth Printing | 2,000 copies | Sep 2010 |


© រក្សាសិទ្ធិដោយ*ព្រះបន្ទូលនៃជីវិត*, ឆ្នាំ ២០០៤, ២០០៩, ២០១០

A Training Book of
***Words of Life Ministries and***
***Antioch Institute***

យើងខ្ញុំទទួលស្វាគមមតិរិះគន់ស្ថាបនា និងយោបល់ផ្សេងៗពីលោកអ្នក។ ប្រសិនបើ
លោកអ្នកឃើញមានកំហុសណាមួយក្នុងសៀវភៅ សូមទំនាក់ទំនងយើងខ្ញុំតាមរយៈប្រអប់
សំបុត្រ ២៥៨១ ភ្នំពេញ ៣ ឬតាមអ៊ីមែលៈ info@asiaforjesus.com សូមអរគុណ!

# មាតិកា

## Table of Contents

| | |
|---|---|
| មេរៀនទី១: កំណើតព្រះយេស៊ូ | ៧ |
| មេរៀនទី១: សេចក្តីពិតខាងវិញ្ញាណ | ១១ |
| មេរៀនទី២: ការជ្រមុជទឹករបស់ព្រះយេស៊ូ | ១៥ |
| មេរៀនទី២: សេចក្តីពិតខាងវិញ្ញាណ | ១៩ |
| មេរៀនទី៣: ការអស្ចារ្យរបស់ព្រះយេស៊ូ | ២៣ |
| មេរៀនទី៣: សេចក្តីពិតខាងវិញ្ញាណ | ២៧ |
| មេរៀនទី៤: សេចក្តីបង្រៀនរបស់ព្រះយេស៊ូ | ២៩ |
| មេរៀនទី៤: សេចក្តីពិតខាងវិញ្ញាណ | ៣៥ |
| មេរៀនទី៥: ការបញ្ជូនព្រះយេស៊ូ | ៣៩ |
| មេរៀនទី៥: សេចក្តីពិតខាងវិញ្ញាណ | ៤៥ |
| មេរៀនទី៦: ការឆ្កាងព្រះយេស៊ូ | ៤៧ |
| មេរៀនទី៦: សេចក្តីពិតខាងវិញ្ញាណ | ៥៣ |
| មេរៀនទី៧: ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ | ៥៥ |
| មេរៀនទី៧: សេចក្តីពិតខាងវិញ្ញាណ | ៦១ |

# របៀបប្រើសៀវភៅរឿងដំណឹងល្អអំពីព្រះយេស៊ូ
# និង
# សៀវភៅចាប់ផ្តើមជីវិតថ្មីជាមួយព្រះគ្រិស្ត

១- ចាប់ផ្តើមការប្រជុំគ្នាដោយមានការអធិស្ឋានខ្លីមួយ ដើម្បីសុំឱ្យល់រឿង។

២- អានរឿងទៅអ្នកដែលចូលរួម ឬក៏អានទាំងអស់គ្នា។

៣- អ្នកដឹកនាំគួរតែសួរសំណួរផ្ទាល់មាត់នៅពេលបញ្ចប់រឿង។ គោលបំណងនៃសំណួរ គឺពិនិត្យទៅលើការយល់ដឹងអំពីរឿង មិនមែនសម្រាប់ពិភាក្សាទេ។

៤- អានសេចក្តីពិតខាងវិញ្ញាណ។ អនុញ្ញាតិឱ្យសមាជិកមានសេរីភាពក្នុងការពិភាក្សាក្នុងសេចក្តីពិតនីមួយៗ។ តែសូមឱ្យប្រុងប្រយ័ត្ន មិនត្រូវប្រកែកគ្នាឡើយ គឺគ្រាន់តែគេយល់សេចក្តីទាំងនោះ។

៥- ទុកពេលឱ្យមានការចែកចាយនូវសំណូមអធិស្ឋានជាក្រុម។

៦- អធិស្ឋានយ៉ាងជាក់លាក់សម្រាប់តម្រូវការនីមួយៗនៅក្នុងក្រុម។

# មេរៀនទី១

# កំណើតព្រះយេស៊ូគ្រិស្ត

ម៉ាថាយ ១-២

*«ដូច្នេះ ចាប់តាំងពីលោកអាប្រាហាំដរាបមកដល់ស្ដេចហ្លួងដាវីឌ រួមទាំងអស់មាន១៤ដំណា ចាប់តាំងពីស្ដេចហ្លួងដាវីឌដ៏រាបមកដល់នឹងគ្រាដែលត្រូវគេនិរទេសជនជាតិអ៊ីស្រាអែលទៅធ្វើជាឈ្លើយនៅស្រុកបាប៊ីឡូន ក៏មាន១៤ដំណា ហើយចាប់តាំងពីគ្រាដែលគេគៀជនជាតិអ៊ីស្រាអែលយកទៅធ្វើជាឈ្លើយ ត្រូវនិរទេសទៅស្រុកបាប៊ីឡូនដរាបមកដល់ព្រះគ្រិស្តក៏មាន១៤ដំណាដែរ»។ (ម៉ាថាយ១:១៧)*

ម៉ារាជាស្ត្រីសាសន៍យូដាមានផ្ទៃពោះដោយគ្មានការរួមដំណេកជាមួយនឹងប្រុសណាម្នាក់ឡើយ តែនាងបានមានគភ៌ដោយព្រោះព្រះវិញ្ញាណបរិសុទ្ធ។ គូដណ្ដឹងរបស់នាងជាបុរសសុចរិតម្នាក់ ដោយមិនចង់ប្រាប់នរណាម្នាក់ឱ្យដឹងជាសាធារណៈឡើយ ដូច្នេះគាត់ក៏ចង់ផ្ដាច់ពាក្យជាមួយនាងដោយសម្ងាត់។ ប៉ុន្តែនៅថ្ងៃដដែលនោះខណៈដែលគាត់កំពុងសម្រេចនឹងធ្វើការនេះ ទេវតានៃព្រះអម្ចាស់បានលេចមកឯគាត់ក្នុងសុបិនហើយប្រាប់គាត់ថា «យ៉ូសែប! ពូជហ្លួងដាវិឌអើយ! កុំឱ្យខ្លាចនឹងយកនាងម៉ារាធ្វើជាប្រពន្ធអ្នកឡើយ ដ្បិតបុត្រដែលមកចាប់កំណើតក្នុងផ្ទៃនាងនោះ កើតពីព្រះវិញ្ញាណបរិសុទ្ធទេ នាងនឹងប្រសូតបុត្រាមួយ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រព្រះអង្គឱ្យរួចពីបាប»។

ម៉ារាជាស្ត្រីដែលព្យាការីអេសាយបាននិយាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់នៅពេលគាត់និយាយថា «មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះបុត្រានោះត្រូវហៅថាអេម៉ាញូអែល» ដែលប្រែថា «ព្រះអង្គព្រះអង្គគង់ នៅជាមួយនឹងយើងខ្ញុំ»។

យ៉ូសែបភ្ញាក់ពីសុបិនឡើងវិញ និងធ្វើតាមទេវតាដែលបានប្រាប់គាត់បានរៀបការជាមួយនឹងម៉ារី ប៉ុន្តែគាត់មិនបានរួមរស់ជាមួយនឹងនាងសោះទាល់តែនាងប្រសូតបុត្រាជាចម្បងមករួចគាត់ថ្វាយព្រះនាមថា «យេស៊ូ» ទៅតាមអ្វីដែលទេវតាបានប្រាប់

កាល ព្រះយេស៊ូ ព្រះអង្គប្រសូត មក នៅ ភូមិ បេថ្លេហិម ស្រុក យូដា នៅ ក្នុង ប្រ ទេស អ៊ីស្រាអែល ហើយស្ដេចនៃស្រុកយូដានៅសម័យនោះមានព្រះនាមថា ហេរ៉ូឌ។

មានពួកព្យាការីដែលមកពីតំបន់អាស៊ីទៅស្រុកយូដា ដោយដើរតាមពន្លឺផ្កាយ។ ដោយយោងទៅតាមការសិក្សារបស់ពួកគេ ផ្កាយនេះបានបង្ហាញពីស្ដេចដែលបានសន្យាបានប្រសូតនៅស្រុកយូដាហើយ ដោយមិនដឹងជាពិតថាទារកនោះប្រសូតនៅកន្លែងណា។ ដំបូងពួកគេបានចូលទៅក្នុងវាំងស្ដេចហេរ៉ូឌជាស្ដេចនៃស្រុកយូដាហើយសួរថា តើព្រះអង្គដែលមកប្រសូតមកធ្វើជាស្ដេចសាសន៍យូដាព្រះអង្គគង់នៅឯណា?

ស្ដេចហេរ៉ូឌកើតក្ដីទុក្ខព្រួយយ៉ាងខ្លាំងចំពោះរឿងដែលពួកគេបានប្រាប់។ស្ដេចបានហៅអស់ពួកសម្ដេចសង្ឃ និងពួកមេដឹកនាំសាសនានៃបណ្ដាជនមកប្រជុំជាសម្ងាត់។ ស្ដេចសួរបុរសទាំងនេះពីកន្លែងទារកតូចដែលបានប្រសូតដោយយោងទៅតាមការទស្សន៍ទាយរបស់សាសន៍យូដា។ ពួកសម្ដេចសង្ឃបានប្រាប់ព្រះអង្គថា ដោយយោងទៅតាមបទគម្ពីរ ទារកតូចនោះបានកើតនៅភូមិបេថ្លេហិម។ ស្ដេចហេរ៉ូឌបានយាងទៅឯពួកព្យាការីសួរពួកគេពីពេលដែលពួកគេបានឃើញផ្កាយពីមុនដំបូង។ ព្រះអង្គចង់សួរនេះពីព្រោះព្រះអង្គចង់ដឹងថ្ងៃកំណើតរបស់បុត្រតូច និងចង់ដឹងពីអាយុរបស់បុត្រនោះ។

ហេរ៉ូឌបានផ្ដល់ដំណឹងដល់ពួកព្យាការីពីទីកន្លែងដែលបុត្រតូចនោះប្រសូត ព្រះអង្គបានទាំងនិយាយផងដែរថា «ចូរទៅ និងស្វែងរកដោយយកចិត្តទុកដាក់ពីបុត្រតូចនោះ ហើយនៅពេលពួកលោករកឃើញបុត្រតូចនោះហើយ សូមមកប្រាប់យើងផងយើងនឹងទៅថ្វាយបង្គំព្រះអង្គផងដែរ»។

ពួកព្យាការីបានចាកចេញពីវាំង ហើយបន្តដើរតាមពន្លឺផ្កាយទៅភូមិបេថ្លេហិម។ ផ្កាយដែលពួកគេបានដើរតាមពីយូរមកហើយនោះ បានទៅឈប់នៅព្រះអង្គផ្ទះដែលបុត្រតូចគង់នៅ។ ពួកគេចូលទៅក្នុងផ្ទះ រំពេចនោះពួកគេបានឃើញបុត្រតូចនៅជាមួយនឹងនាងម៉ារាដែលជាមាតាព្រះអង្គ។ ពួកគេក្រាបចុះ ហើយថ្វាយបង្គំព្រះអង្គ ពួកគេបានប្រទានដល់ព្រះអង្គនូវអំណោយដ៏មានតម្លៃ ជាមាស កំញាន និងជ័រល្វីងទេស។

ដូច្នេះ ពួកព្យាការីបានចាកចេញពីកន្លែងទៅផ្ទះរបស់ខ្លួនវិញនៅភាគខាងកើត ប៉ុន្តែមុននឹងពួកគេចាកចេញ ពួកគេបានយល់សុបិនដោយមិនឱ្យពួកគេវិលត្រលប់

ទៅឯស្តេចហេរ៉ូឌ និងប្រាប់ស្តេចពីរបៀបនឹងរកបុត្រនោះឡើយ។ ដូច្នេះពួកគេបានទៅផ្ទះវិញតាមផ្លូវផ្សេង។

ក្រោយពីពេលដែលពួកគេចាកចេញទៅ យ៉ូសែបបានយល់សប្តិមួយទៀត។ នៅក្នុងការយល់សប្តិនេះព្រះជាម្ចាស់បានប្រមានគាត់ថា ហេរ៉ូឌកំពុងតាមរកបុត្រតូច ហើយឱ្យនាំបុត្រតូចភៀសខ្លួនចេញទៅប្រទេសអេស៊ីព្ទ។ ដូច្នេះនៅពេលយប់នោះគាត់ក៏ភ្ញាក់ឡើង និងចេញទៅយ៉ាងប្រញាប់។ ពួកគេទៅរស់នៅឯប្រទេសអេស៊ីព្ទរហូតដល់ស្តេចហេរ៉ូឌស្លាប់ ដើម្បីឱ្យបានសម្រេចសេចក្តីដែលព្រះអម្ចាស់ព្រះអង្គប្រាប់ដោយសារព្យាការីហូសេថា «យើងបានហៅកូនយើងចេញពីស្រុកអេស៊ីព្ទមក»។

លុះហេរ៉ូឌឃើញថា ពួកព្យាការីបានបញ្ឆោតព្រះអង្គ នោះព្រះអង្គមានសេចក្តីក្រេវក្រោធជាខ្លាំង ក៏ចាត់គេឱ្យទៅសម្លាប់អស់ទាំងក្មេងប្រុសៗនៅបេថ្លេហិមនឹងក្នុងក្រវល់ស្រុកនោះទាំងអស់តាំងពីអាយុ២ឆ្នាំចុះមកនោះបានសម្រេចសេចក្តីទំនាយដែលព្យាការីយេរេមាបានទាយទុក។

ក្រោយពីស្តេចហេរ៉ូឌបានសោយទិវង្គត នោះទេវតានៃព្រះអម្ចាស់លេចមកពន្យល់សប្តិប្រាប់យ៉ូសែបឱ្យគាត់ត្រលប់ទៅអ៊ីស្រាអែលវិញ។ ទោះបីជាយ៉ាងណាក៏ដោយក៏យ៉ូសែបនៅមានការខ្លាចរអាខ្លះដែរ ដោយព្រោះបុត្ររបស់ហេរ៉ូឌនៅកាន់កាប់ស្រុកយូដានៅឡើយ។ ដូច្នេះគាត់ក៏យកគ្រួសាររបស់គាត់ទៅនៅស្រុកកាលីឡេក្នុងក្រុងមួយហៅថាណាសារ៉ែត។ ព្រះយេស៊ូរស់នៅទីនោះតាំងពីតូចដើម្បីឱ្យបានសម្រេចសេចក្តីដែលពួកព្យាការីបានថ្លែងថា «គេនឹងហៅព្រះអង្គជាអ្នកក្រុងណាសារ៉ែត»។

## សំណួរផ្ទាល់មាត់

១. តើម៉ារាជានរណា?

២. តើទេវតាលេចមកឯអ្នកណា និងប្រាប់ឱ្យដាក់ឈ្មោះអ្វីដល់ទារកនោះ?

៣. ហេតុអ្វីបានជាព្យាការីមកពីតំបន់អាស៊ីទៅស្រុកយូដា?

៤. ហេតុអ្វីបានជាស្តេចហេរ៉ូឌចង់ស្វែងរកព្រះយេស៊ូ?

៥. តើពួកព្យាការីដឹងថាពួកគេគួរតែទៅផ្ទះផ្លូវផ្សេង និងគេចពីហេរ៉ូឌដោយរបៀបណា?

៦. តើហេរ៉ូឌមានបំណងនឹងសម្លាប់ស្តេចសន្យានៃសាសន៍យូដាដោយរបៀបណា?

៧. តើយ៉ូសែបដឹងថាគាត់ត្រូវភៀសខ្លួនទៅនៅប្រទេសអេស៊ីព្ទដោយរបៀបណា?

៨. តើយ៉ូសែបដឹងថានៅពេលណាមានសុវត្ថិភាពនឹងត្រលប់មកស្រុកកំណើតវិញដោយរបៀបណា?

៩. ហេតុអ្វីបានជាយ៉ូសែបយកគ្រួសាររបស់គាត់មកឯស្រុកកាលីឡេជំនួសស្រុកយូដាទៅវិញ?

១០.តើក្រុងដែលព្រះយេស៊ូបានរស់នៅកាលពីព្រះអង្គនៅតូចឈ្មោះអ្វី?

## មេរៀនទី១

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ១-២

១. ព្រះជាម្ចាស់ស្មោះត្រង់ និងតែងតែរក្សាសេចក្តីសន្យារបស់ព្រះអង្គ

ចាប់តាំងពីការបង្កើតមនុស្សប្រុសស្រីដំបូង ព្រះជាម្ចាស់បានមានបន្ទូលសន្យាថា ព្រះអង្គនឹងចាត់ព្រះអង្គសង្គ្រោះមកលើផែនដី។ អស់រយៈពេលជាច្រើនឆ្នាំព្រះអង្គបានមានបន្ទូលសេចក្តីសន្យានេះម្តងហើយម្តងទៀតជាច្រើនដងទៅកាន់ប្រជារាស្ត្ររបស់ព្រះអង្គ។ ជាញឹកញាប់ព្រះអង្គបានប្រាប់ដោយលំអិតថាការនេះនឹងកើតឡើងដោយរបៀបណា។ ព្រះយេស៊ូយាងមកលើផែនដីជាពិតដូចដែលបានថ្លែងទុកនៅក្នុងបទគម្ពីរ។ សូមយើងចងចាំនូវរឿងនេះយ៉ាងហោចណាស់ពីការប្រាប់ឱ្យដឹងជា-មុនមួយដែលត្រូវបានសម្រេចតាមរយៈតាមកំណើតនៃព្រះយេស៊ូ។

*** ព្រះជាម្ចាស់ ស្មោះ ត្រង់ ចំពោះ យើង ក្នុង របៀប ដូច គ្នា ដែរ** នៅ ក្នុង ព្រះគម្ពីរ មាន សេចក្តី សន្យា សំខាន់ៗ ជា ច្រើន ដែល ព្រះ ជាម្ចាស់ បាន ធ្វើ អំពី គម្រោងការណ៍ របស់ព្រះអង្គសម្រាប់យើង។ ព្រះអង្គនឹងបំពេញសេចក្តីសន្យា និងសេចក្តីថ្លែងប្រាប់ឱ្យដឹងជាមុនទាំងអស់នេះ។ វាមានសារៈសំខាន់បំផុតសម្រាប់យើងទាំងអស់គ្នាដើម្បីនឹងអានព្រះគម្ពីរ និងស្វែងរកមើលនូវព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់យើងទាំងអស់គ្នា។

២. ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយអ្វីៗទាំងអស់នៅក្នុងសុទ្ធតែនោះជាសេចក្តីពិត

ព្រះជាម្ចាស់បានមានបន្ទូលទុកជាមុនទៅតាមព្យាការីរបស់ព្រះអង្គអស់រយៈពេលជាច្រើនពាន់ឆ្នាំមកហើយចំពោះការលំអិតដ៏ជាក់លាក់ជាច្រើនទាក់ទងនឹងការប្រសូត និងជីវិតរបស់ព្រះយេស៊ូគ្រិស្ត។ ការគ្រប់យ៉ាងបានកើតឡើងជាពិតដូចដែលបានទស្សន៍ទាយទុក។

៣. ព្រះជាម្ចាស់គ្រប់គ្រងលើរបស់ទាំងអស់

ព្រះអង្គអាចធ្វើឱ្យការអស្ចារ្យជាច្រើនកើតឡើង មានការអស្ចារ្យខាងឯធម្មជាតិ និងការអស្ចារ្យជាច្រើនទៀតបានកើតឡើងនៅក្នុងរឿងនេះ។ យ៉ាងហោចណាស់ការអស្ចារ្យមួយក្នុងចំណោមការអស្ចារ្យទាំងនេះគឺជាអ្វី?

៤. ព្រះជាម្ចាស់អាចទំនាក់ទំនងជាមួយនឹងមនុស្ស

អ្នកខ្លះជឿថា ព្រះជាម្ចាស់បានបង្កើតពិភពលោក ប៉ុន្តែព្រះអង្គមិនបានយកចិត្តទុកដាក់ចំពោះការអ្វីដែលកើតឡើងនៅទីនេះនោះទេ។ តើព្រះជាម្ចាស់មានទំនាក់ទំនងជាមួយនឹងមនុស្សនៅក្នុងរឿងនេះដោយរបៀបណា?។ ព្រះជាម្ចាស់នៅតែមានទំនាក់ទំនងជាមួយនឹងយើងនៅថ្ងៃនេះយើងនឹងរៀនទៅតាមការសិក្សានេះពីរបៀបដែលយើងនឹងមានទំនាក់ទំនងដ៏ពិតប្រាកដជាមួយនឹងព្រះជាម្ចាស់។

៥. ព្រះជាម្ចាស់ជ្រាបគ្រប់ការទាំងអស់ដែលនឹងត្រូវកើតឡើង ប៉ុន្តែនៅពេលខ្លះនៅក្នុងព្រះប្រាជ្ញាញាណរបស់ព្រះអង្គជាព្រះ ព្រះអង្គអនុញ្ញាតឱ្យការអាក្រក់កើតឡើង

ហេរ៉ូឌចង់សម្លាប់បុត្រតូច ពីព្រោះព្រះអង្គ មានអារម្មណ៍ភ័យខ្លាចនឹងព្រះយេស៊ូ។ ព្រះជាម្ចាស់ជ្រាបពីអំពើបាបដ៏ខ្មៅកខ្វក់នៅក្នុងចិត្តរបស់ ហេរ៉ូឌ ព្រះអង្គជ្រាបថាហេរ៉ូឌនឹងសម្លាប់កូនក្មេងដែលមិនទាន់ដឹងក្តីរាប់រយនាក់។ ដោយសារតែការមិនស្តាប់បង្គាប់និងការបះបោរនៅក្នុងចិត្តរបស់ស្តេចហេរ៉ូឌការអាក្រក់ដ៏ធំមួយបានកើតឡើង។ សព្វថ្ងៃនេះការអាក្រក់ជាច្រើនកើតឡើងដោយសារតែការមិនស្តាប់បង្គាប់និងការប្រឆាំងមាននៅក្នុងជីវិតរបស់យើង។ តើលោកអ្នកមានដឹងពីឧទាហរណ៍នៅសម័យនេះដែលអ្នកខ្លះបានត្រូវទទួលការឈឺចាប់ដោយសារតែភាពឃោរឃៅរបស់អ្នកផ្សេងទៀតដែរឬទេ?

៦. មនុស្សមិនអាចប្រឆាំងនឹងព្រះជាម្ចាស់និងយកឈ្នះលើព្រះអង្គបានឡើយ

ហេរ៉ូឌមិនអាចនឹងសម្លាប់បុត្រតូចបានទេ។ ការតែមួយគត់ដែលគាត់អាចសម្រេចបាន គឺបង្កើតនូវសោកនាដកម្មដ៏ឃោរឃៅបំផុតនៅក្នុងជីវិតនៃក្រុមគ្រួសារជាច្រើន។ សព្វថ្ងៃនេះ មានពេលជាច្រើនយើងព្យាយាមដើម្បីបំពានលើក្រិត្យវិន័យរបស់ព្រះជាម្ចាស់ និងបំណងព្រះហឫទ័យរបស់ព្រះអង្គ។ ការនេះតែងតែនាំមកនូវសោកនាដកម្មប្រសិនជាមិនមែនសម្រាប់យើងក៏សម្រាប់អស់អ្នកដែលនៅជុំវិញខ្លួនយើងដែលកំពុងទទួលរងនូវការឈឺចាប់។ តើលោកអ្នកអាចគិតពីពេលវេលានៅក្នុងជីវិតរបស់ខ្លួនដែលធ្វើខុស និងនាំមកនូវសោកនាដកម្មចូលមកក្នុងជីវិតរបស់ខ្លួនឯង

ដែរឬទេ? តើអ្នកអាចគិតឃើញពីពេលវេលានៅពេលលោកអ្នកទទួលការឈឺចាប់ ដោយសារតែការប្រឆាំងរបស់អ្នកដទៃដែរឬទេ?

### ៧. ពួកសម្ដេចសង្ឃ និងអ្នកដឹកនាំសាសនាបានដឹងពីបទគម្ពីរដែលនិយាយពីបុត្រតូចដែរ ប៉ុន្ដែពួកគេមិនបានចូលទៅគាល់ព្រះយេស៊ូទេ

តើវាអាចកើតឡើងបានដែរឬទេ ចំពោះអ្នកដែលជំនឿមុតមាំក្នុងសាសនាដឹងច្រើនអំពីព្រះគម្ពីរ ដឹងច្រើនពីព្រះយេស៊ូគ្រិស្ដ ប៉ុន្ដែមិនដែលធ្លាប់ស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់ក្នុងចិត្ដរបស់គេផងនោះ?

### ៨. ព្រះយេស៊ូជា «ព្រះជាម្ចាស់គង់នៅជាមួយ» ឬ «អេម៉ាញូអែល»

ទេវតាបាននិយាយនូវពាក្យទាំងនេះទៅកាន់យ៉ូសែបដែលបានកត់ត្រាទុកនៅក្នុងបទគម្ពីរដោយព្យាការីអេសាយ។ មនុស្សជាច្រើនបាននិយាយថា ព្រះយេស៊ូជាព្យាការី អ្នកផ្សេងទៀតនិយាយថា ព្រះអង្គជាទេវតាឬក៏ជាមនុស្សល្អម្នាក់។ ប៉ុន្ដែព្រះជាម្ចាស់គម្ពីរបានបង្រៀនយើងថា ព្រះអង្គជា «ព្រះជាម្ចាស់គង់នៅជាមួយយើង»។

នៅក្នុង៦សប្ដាហ៍បន្ទាប់ យើងនឹងព្យាយាមស្វែងរកមើលថា អ្នកណាជាព្រះយេស៊ូជាពិត និងតើអ្វីទៅជាដំណឹងល្អដែលព្រះអង្គបាននាំមកផែនដី។

## មេរៀនទី២

# ការប្រសូតរបស់ព្រះយេស៊ូ

ម៉ាថាយ ៣-៤

*«ចូរប្រែចិត្តគំនិតឡើង ដ្បិតព្រះរាជនៃស្ថានបរមសុខមកជិតបង្កើយហើយ ឱ្យប្រែចិត្តចុះដ្បិតនគរស្ថានសួគ៌ជិតមកដល់ហើយ» ម៉ាថាយ ៣:២។*

រំឭក

១. ឈ្មោះរបស់មាតាព្រះយេស៊ូគឺ______________________________

២. ការអស្ចារ្យមួយក្នុងកំណើតព្រះយេស៊ូគឺថាទ្រង់ប្រសូតមកនឹង__________

______________________________________________________

៣. ព្រះគម្ពីរសញ្ញាចាស់បានចែងទុកជាច្រើនអំពីកំណើតព្រះយេស៊ូ__________ ______មួយក្នុងចំណោមការទាំងនេះគឺព្រះអង្គត្រូវបានហៅជាអេម៉ាញូអែលដែលមានន័យថា «ព្រះ____________________»។

៤. ហេរ៉ូឌគឺជា_____________នៃស្រុកយូដាដែលព្យាយាមសម្លាប់ព្រះយេស៊ូ។ ស្ដេចអង្គនេះ_________________អស់ទាំងក្មេងដែលមានអាយុក្រោម២ឆ្នាំដែលរស់នៅក្នុង និងជុំវិញភូមិបេថ្លេហិម។

៥. ពួកព្យាការីដែលចេញទៅស្វែងរកព្រះយេស៊ូដោយដើរតាម____________ ពួកគេបានទៅផ្ទះគេវិញតាមផ្លូវផ្សេង ពីព្រោះព្រះអង្គបានប្រាប់ពួកគេតាមរយៈ___ ____________ថាហេរ៉ូឌមានបំណងចង់______________ព្រះយេស៊ូ។

៦. យ៉ូសែបបានចាកចេញជាមួយនឹងគ្រួសាររបស់គាត់នៅវេលាពាក់កណ្ដាលយប់ទៅប្រទេសអេស៊ីព្ទ ពីព្រោះព្រះជាម្ចាស់បានបង្ហាញគាត់នៅក្នុង__________ ថាហេរ៉ូឌកំពុងតាមមកពីក្រោយ____________________________។

៧. យ៉ូសែបដឹងថាមានសុវត្ថិភាពនឹងត្រលប់ទៅប្រទេសអ៊ីស្រាអែលតាម_____។

គាត់មិនបានត្រលប់ទៅភូមិបេថ្លេហិមវិញនោះទេ តែផ្ទុយទៅវិញគាត់បានយកគ្រួសាររបស់គាត់ទៅទីក្រុងមួយដែលហៅថា______________________។

៨. ដូចដែលព្រះអង្គបានធ្វើគ្រប់ការទាំងអស់តាមរយៈប្រវត្តិសាស្ត្រសព្វថ្ងៃនេះ ព្រះជាម្ចាស់នៅតែថែរក្សា________________________របស់ព្រះអង្គជានិច្ច។

៩. ព្រះជាម្ចាស់ជ្រាបនូវអ្វីដែលមាននៅក្នុង_______________របស់យើងទោះបីជាមានការអាក្រក់ជាច្រើននៅក្នុងនោះក៏ដោយ។

១០. វានឹងអាចធ្វើទៅបានចំពោះការក្លាយជាមនុស្សដែលមានជំនឿរឹងមាំខាងឯសាសនា និងចេះដឹងច្រើនអំពីព្រះគម្ពីរ ប៉ុន្តែនៅតែមិនស្គាល់__________ដោយផ្ទាល់នៅក្នុង________________________របស់គេដែរ។

ទាំងនេះគឺជាពាក្យសម្តីដែលត្រូវបានបង្រៀនដោយបុរសម្នាក់នៅទីរហោស្ថាននៃស្រុកយូដា។ បុរសម្នាក់នេះប្រដាប់ខ្លួនដោយសំពត់ធ្វើពីរោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះក៏បរិភោគកណ្តូប និងទឹកឃ្មុំព្រៃជាអាហារ ឈ្មោះរបស់គាត់គឺយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក។

មនុស្សជាច្រើនមកពីកន្លែងជុំវិញអូរយ័រដាន់បានចេញទៅឯទីរហោស្ថានដើម្បីនឹងស្តាប់ការបង្រៀនរបស់គាត់។ ក្រោយពីស្តាប់ការបង្រៀនរបស់គាត់រួចហើយមនុស្សជាច្រើនបានទទួលពិធីជ្រមុជទឹកនៅក្នុងអូរយ័រដាន់ លន់តួបាបរបស់ពួកគេ។ អ្នកដឹកនាំសាសនាខ្លះខាងគណៈសាដូស៊ី និងផារិស៊ីក៏បានចេញទៅមើលអ្វីដែលបានកើតឡើងនៅក្នុងទីរហោស្ថានផងដែរ។

នៅពេលយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកបានឃើញពួកគេ គាត់បានហៅពួកគេថា *«ឱពូជពស់វែកអើយ»* ជាងនេះទៅទៀតគាត់បាននិយាយថាពួកគេមិនបានកោតខ្លាចដល់ព្រះជាម្ចាស់សោះឡើយ ពីព្រោះពួកគេគិតថាពួកគេរឹងមាំ និងធ្វើល្អគ្រប់គ្រាន់ដែលមិនចាំបាច់ទទួលការលន់តួបាបនោះទេ។

នៅពេលលោកយ៉ូហានកំពុងបង្រៀន ព្រះយេស៊ូបានយាងចូលមក និងសុំយ៉ូហានជ្រមុជទឹកឱ្យព្រះអង្គ។ មុនដំបូងយ៉ូហានមិនចង់ធ្វើទេ ពីព្រោះគាត់គិតថាគាត់មិនសក្តិសមនឹងជ្រមុជទឹកឱ្យព្រះយេស៊ូទេ។ ប៉ុន្តែព្រះយេស៊ូសុំឱ្យគាត់ធ្វើការនេះ ហើយពួកគេទាំងពីរក៏ដើរចូលទៅក្នុងអូរយ័រដាន់។ នៅពេលព្រះយេស៊ូងើបចេញពីទឹកឡើងមកវិញ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកពីស្ថានសួគ៌សណ្ឋិតលើព្រះអង្គក្នុងសណ្ឋានជារូបព្រាប។ ក៏មានសម្លេងលាន់ឮរំពងចេញពីស្ថានសួគ៌មក

និយាយថា *«នេះជាកូនស្ងួនភ្ងារបស់យើង ជាទីពេញចិត្តយើងណាស់»* ។

ក្រោយ មក ព្រះវិញ្ញាណ បរិសុទ្ធ យក ព្រះអង្គទៅ ឯ ទី រហោ ស្ថាន ដើម្បី នឹងឱ្យអារក្សល្បួងព្រះអង្គ។ ព្រះអង្គតមអាហារ និងទឹករយៈពេល៤០ថ្ងៃ៤០យប់ហើយបន្ទាប់ពី៤០ថ្ងៃនោះ ព្រះអង្គឃ្លានជាខ្លាំង នៅពេលនោះហើយដែលអារក្សចូលមកដើម្បីល្បួងព្រះយេស៊ូគ្រិស្ត។

ព្រះគម្ពីរប្រាប់យើងអំពីសេចក្ដីល្បួងបីយ៉ាងដែលព្រះយេស៊ូបានជួបប្រទះនៅទីរហោស្ថាន។ នៅក្នុងសេចក្ដីល្បួងដំបូងបំផុតអារក្សព្យាយាមនឹងឱ្យព្រះយេស៊ូធ្វើឱ្យដុំថ្មក្លាយទៅជានំប៉័ងដើម្បីបង្ហាញថាព្រះអង្គ ជាព្រះ ។ព្រះយេស៊ូបានឆ្លើយទៅអារក្សវិញដោយប្រើនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ទីពីរអារក្សបានយកព្រះអង្គទៅឯទីខ្ពស់នៃព្រះវិហារ និងឱ្យព្រះអង្គលោតពីលើមកដើម្បីបង្ហាញថាព្រះអង្គជាព្រះ ប៉ុន្តែព្រះយេស៊ូបានឆ្លើយទៅអារក្សម្តងទៀតដោយប្រើនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងព្រះគម្ពីរ។ ចុងក្រោយអារក្សដឹកនាំព្រះអង្គទៅលើភ្នំនិងនិយាយថា «យើងនឹងឱ្យរបស់ទាំងអស់នេះទៅដល់អ្នកប្រសិនជាអ្នកថ្វាយបង្គំយើង» ព្រះយេស៊ូឆ្លើយទៅអារក្សដោយមានបន្ទូលថា *«ឯងត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែមួយព្រះអង្គប៉ុណ្ណោះ»*។

ក្រោយពីត្រលប់ពីមកទីរហោស្ថានវិញ ព្រះយេស៊ូបានឮថា លោកយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកត្រូវបានគេចាប់ដាក់គុក។ បន្ទាប់មកព្រះយេស៊ូបានយាងទៅស្រុកកាលីឡេនៅភាគខាងជើងស្រុកយូដា ចាកចេញពីក្រុងរបស់ព្រះអង្គ គឺក្រុងណាសារ៉ែតដោយចេញទៅស្រុកកាពើណិម។ ការនេះបានសម្រេចសេចក្ដីដែលព្យាការីអេសាយបានថ្លែងទុកថា «ស្រុកសាប់យ៉ូលូន និងណែបថាលីតាមផ្លូវទៅឯសមុទ្រខាងនាយអូរយ័រដាន់គឺជាស្រុកកាលីឡេរបស់សាសន៍ដទៃ ឯបណ្តាជនដែលអង្គុយក្នុងសេចក្ដីងងឹតគេបានឃើញពន្លឺយ៉ាងធំ មានពន្លឺរះឡើងបំភ្លឺដល់ពួកអ្នកដែលអង្គុយក្នុងអន្លង់ហើយ និងម្លប់នៃសេចក្ដីស្លាប់»។

ព្រះគម្ពីរប្រាប់យើងថាពីក្រុងនេះព្រះយេស៊ូបានចាប់ផ្តើមកិច្ចការរបស់ព្រះអង្គក្នុងចំណោមបណ្តាជនជាច្រើន។ សារដែលព្រះអង្គបានបង្រៀនគឺ «ចូរប្រែចិត្តចុះដ្បិតនគរស្ថានសួគ៌មកដល់ហើយ»។

## សំណួរផ្ទាល់មាត់

១. ចូរពិពណ៌នាអំពីបុរសម្នាក់ឈ្មោះយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក។

២. តើដំណឹងអ្វីដែលយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកបានចែកចាយ?

៣. តើយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកបានធ្វើអ្វីជាមួយនឹងអ្នកដែលបានលន់តួនូវអំពើបាបរបស់ពួកគេ?

៤. ហេតុអ្វីបានជាយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកមិនចង់ជ្រមុជទឹកឱ្យព្រះយេស៊ូ?

៥. តើព្រះយេស៊ូទទួលពិធីជ្រមុជទឹកដោយរបៀបណា?

៦. តើមានអ្វីកើតឡើងនៅពេលព្រះយេស៊ូយាងចេញមកពីទឹកវិញ?

៧. ហេតុអ្វីបានជាព្រះយេស៊ូយាងទៅទីរហោស្ថាន?

៨. តើព្រះយេស៊ូធ្វើអ្វីនៅក្នុងកំឡុងពេល៤០យប់៤០ថ្ងៃ?

៩. តើសេចក្ដីល្បួងអ្វីក្នុងចំណោមសេចក្ដីល្បួងរបស់អារក្ស?

១០.ក្រោយពីទទួលសេចក្ដីល្បួង តើអ្នកណាមកបម្រើព្រះយេស៊ូ?

១១.តើព្រះយេស៊ូយាងទៅណាក្រោយពីដឹងថា យ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកត្រូវបានគេចាប់?

១២.តើដំណឹងអ្វីដែលព្រះយេស៊ូបានចែកចាយ? តើអ្នកណាបានបង្រៀនដូចគ្នានឹងដំណឹងនេះដែរ?

## មេរៀនទី២

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ៣-៤

១. ដំណឹងរបស់យ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក និងដំណឹងរបស់ព្រះយេស៊ូគឺជាដំណឹងដូចគ្នា *«ចូរប្រែចិត្តចុះដ្បិតនគរស្ថានសួគ៌ជិតមកដល់ហើយ»*

- ប្រែចិត្តមានន័យថា បែរចេញពីអំពើបាបនៅក្នុងជីវិតរបស់លោកអ្នក។ វាមានន័យថាប្រគល់នូវជីវិតរបស់លោកអ្នកទាំងស្រុងឱ្យព្រះយេស៊ូគ្រិស្តដឹកនាំ។

- អំពើបាប គឺជាការមិនគោរពកោតខ្លាចដល់ព្រះជាម្ចាស់ និងក្រិត្យវិន័យរបស់ព្រះអង្គ។

- តើការប្រែចិត្តជាការពិបាកសម្រាប់មនុស្សម្នាក់នឹងធ្វើឬ?

- តើពាក្យនេះមានន័យយ៉ាងដូចម្ដេចសម្រាប់លោកអ្នក?

ចូរពិភាក្សាពីគោលគំនិតនេះជាមួយនឹងសមាជិកនៅក្នុងក្រុមរបស់លោកអ្នក ចូរឱ្យពួកគេម្នាក់ៗមានឱកាសនឹងបញ្ចេញនូវគំនិតរបស់ពួកគេរៀងៗខ្លួន។

២. អ្នកដឹកនាំសាសនាគិតថា ពួកគេមិនត្រូវការប្រែចិត្តចេញពីអំពើបាបរបស់ពួកគេឡើយដោយសារតែសាសនារបស់ពួកគេ។ ពួកគេគិតថា ពួកគេល្អគ្រប់គ្រាន់ហើយ។ លោកយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹកបានហៅពួកមនុស្សទាំងនោះថា ជាពូជពស់វែក។ តើមាននរណាម្នាក់នៅលើលោកនេះធ្វើល្អគ្រប់គ្រាន់ដែលពួកគេមិនចាំបាច់ប្រែចិត្តចេញពីអំពើបាបរបស់ពួកគេដែរឬទេ?

*ព្រះគម្ពីររ៉ូម ៣:២៣ ចែងថា «ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះជាម្ចាស់»

*តើមាននរណាម្នាក់លើលោកយើងនេះមិនដែលធ្វើបាបទាល់តែសោះនៅក្នុងជីវិតរបស់ពួកគេដែរឬទេ? តើមាននរណាម្នាក់មិនដែលមិនស្ដាប់បង្គាប់ព្រះជាម្ចាស់ដែរឬទេ? ព្រះគម្ពីរចែងថា «គ្មានទេ»។ តើលោកអ្នកយល់ស្របតាមព្រះគម្ពីរដែរទេថា យើងទាំងអស់គ្នាបានប្រព្រឹត្តអំពើបាបនៅក្នុងជីវិតរបស់យើង?

វាមានសារៈសំខាន់ណាស់នឹងឱ្យមនុស្សម្នាក់មាន ឱកាស រៀន នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងមេរៀនទាំងនេះ។ ជាអ្នកដឹកនាំមិនត្រូវឈ្លោះប្រកែក ឬឱ្យនរណាម្នាក់ផ្សេងទៀតឈ្លោះប្រកែកនោះទេ។ ប៉ុន្តែ វាមិនជាបញ្ហាអ្វីនោះទេនឹងឱ្យមនុស្សបញ្ចេញនូវអារម្មណ៍របស់ពួកគេ។

**៣. ព្រះយេស៊ូបានទទួលពិធីជ្រមុជទឹក ប៉ុន្តែព្រះអង្គជាព្រះមិនដែលធ្វើបាបអ្វីសោះឡើយ**

ការនេះប្រាប់យើងថា ពិធីជ្រមុជទឹកមិនមែនជាពិធីសាសនាដែលអាចដោះអំពើបាបចេញពីជីវិតរបស់មនុស្សបាននោះទេ។ ប្រសិនជាគោលបំណងនៃពិធីជ្រមុជទឹកគឺសម្រាប់លាងមនុស្សឱ្យស្អាតពីអំពើបាប នោះព្រះយេស៊ូមិនចាំបាច់ធ្វើពិធីជ្រមុជទឹកនោះទេ ពីព្រោះព្រះអង្គជាព្រះ ព្រះអង្គមិនដែលប្រព្រឹត្តអំពើបាបនោះទេ។

**៤. នៅពេលព្រះយេស៊ូងើបពីទឹកឡើងមកវិញព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើព្រះអង្គក្នុងសណ្ឋានជាសត្វព្រាប ហើយព្រះវរបិតាមានព្រះបន្ទូលពីស្ថានសួគ៌មកដោយបន្ទូលថា «នេះជាកូនស្ងួនភ្ងារបស់យើង ជាទីពេញចិត្តយើងណាស់» ។** នៅត្រង់នេះយើងឃើញអំពីព្រះត្រៃឯក តើព្រះអង្គទាំងបីគឺនរណាខ្លះ ?

គឺ <u>ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ</u>។

**៥.** ព្រះយេស៊ូត្រូវបានយកចេញទៅទីរហោស្ថានដើម្បីឱ្យអារក្សល្បួង។ អារក្សគឺមានពិតប្រាដក វាគឺជាវិញ្ញាណដែលនៅក្នុងលោកីយនេះជាមួយនឹងវិញ្ញាណដែលដើរតាមវាជាច្រើនទៀតហៅថាវិញ្ញាណអាក្រក់និងអាចនាំមកនូវការបំផ្លាញដល់ជីវិតរបស់យើងដោយដឹកនាំយើងមិនគោរពកោតខ្លាចព្រះជាម្ចាស់ ។ ដូចដែលវាបានល្បួងព្រះយេស៊ូ អារក្សក៏ល្បួងយើងដូច្នោះដែរ។ ប៉ុន្តែ ព្រះគម្ពីរបង្រៀនយើងថា យើងមិនបានទទួលសេចក្តីល្បួងដូចជាព្រះគ្រិស្តនោះទេគឺត្រូវទទួលសេចក្តីល្បួងដោយការអាក្រក់ដែលកើតមានរួចមកហើយនៅក្នុងចិត្តរបស់យើង ដើម្បីនឹងធ្វើការណាដែលមិនសព្វព្រះហឫទ័យដល់ព្រះជាម្ចាស់ ឬក៏ធ្វើអំពើបាប។

**៦.** ព្យាការីអេសាយបានថ្លែងទុកជាមុនថា ព្រះយេស៊ូនឹងរស់នៅក្នុងផ្លូវនៃសមុទ្រ ហើយជាពន្លឺដល់មនុស្សទាំងអស់ដែលរស់នៅក្នុងសេចក្តីងងឹត ហើយដល់អស់អ្នកដែលរស់នៅក្នុងស្រមោលនៃសេចក្តីស្លាប់។

បើគ្មានព្រះគ្រិស្តទេ យើងទាំងអស់គ្នារស់នៅក្នុងសេចក្តីងងឹត។ ប៉ុន្តែ ប្រហែល

ជាលោកអ្នកឬក៏អ្នកដែលលោកអ្នកស្រឡាញ់កំពុងរស់នៅក្នុងស្រមោលនៃសេចក្តីស្លាប់ អ្នកខ្លះបានដឹងថាខ្លួនឯងនៅទីនោះដោយសារថ្នាំញៀន ទំនាក់ទំនងអសីលធម៌។ ខនេះប្រាប់យើងថា ព្រះយេស៊ូមកដើម្បីប្រទានពន្លឺដល់អស់អ្នកដែលនៅក្នុងសេចក្តីងងឹត ហើយព្រះអង្គអាចប្រទានសេរីភាពដល់អស់អ្នកដែលរស់នៅក្នុងម្លប់នៃសេចក្តីស្លាប់ផងដែរ។

*នៅក្នុងពេលអធិស្ឋានរបស់យើងថ្ងៃនេះ ចូរអធិស្ឋានសម្រាប់អស់អ្នកដែលយើងស្រឡាញ់ ហើយដែលកំពុងរស់នៅក្នុងម្លប់នៃសេចក្តីស្លាប់ សូមឱ្យពួកគេអាចរកឃើញពន្លឺ និងសេរីភាពក្នុងព្រះគ្រិស្ត។

# មេរៀនទី៣

## ការអស្ចារ្យរបស់ព្រះយេស៊ូ

ម៉ាថាយ ៤-៩

*«សូមអញ្ជើញមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឱ្យនេសាទមនុស្សវិញ»*

ម៉ាថាយ ៤:១៩។

វិញក

១. តើនរណាប្រាប់យ៉ូសែបអំពីការយាងមករបស់ព្រះយេស៊ូ និងប្រាប់ដល់គាត់ថា ព្រះនាមព្រះអង្គនឹងជា «អេម៉ាញូអែល» ឬ «ព្រះជាម្ចាស់គង់នៅជាមួយ»? ការនេះបង្រៀនយើងថាព្រះយេស៊ូគឺ________________________ជាមួយយើង។

២. តើនរណាចង់សម្លាប់បុត្រតូចយេស៊ូ? ហេតុអ្វី? ព្រះយេស៊ូបានភៀសខ្លួនដោយព្រោះពួកគេ________________________________________។

៣. តើនរណាជ្រមុជទឹកឱ្យព្រះយេស៊ូ? ជាការពិតគឺថា ព្រះជាម្ចាស់ត្រូវទទួលពិធីជ្រមុជទឹកដើម្បីបង្ហាញយើងថា ពិធីជ្រមុជទឹកមិនមែនជា________________ នៅក្នុងជីវិតរបស់យើងបានទេ។

៤. នៅពេលព្រះយេស៊ូយាងចេញពីក្នុងទឹកមកមានអ្វីមួយសណ្ឋានជារូបព្រាបចុះពីស្ថានសួគ៌មក និងសម្លេងនិយាយចេញមកពីស្ថានសួគ៌។ តើនរណាជាព្រាប និងសម្លេងអ្នកណាចេញមកពីស្ថានសួគ៌?

៥. ពួកអ្នកខាងគណៈផារិស៊ីគិតថា ពួកគេមិនត្រូវការការប្រែចិត្តចេញពីអំពើបាបរបស់ពួកគេនោះទេ ពីព្រោះពួកគេមានជំនឿរឹងមាំណាស់នឹងសាសនារបស់ពួកគេ តើវានឹងអាចកើតឡើងទៅបានទេសម្រាប់អ្នកណាម្នាក់ដែលមានជំនឿរឹងមាំគ្រប់គ្រាន់ដើម្បីនឹងអាចលាងនូវអំពើបាបរបស់គេបាន?

៦. តើពាក្យថា «ប្រែចិត្ត» មានន័យថាយ៉ាងដូចម្តេច?

៧. តើអ្វីទៅជាអំពើបាប?

៨. តើអ្នកណាល្បួងព្រះយេស៊ូនៅទីរហោឋាន?

នៅពេលព្រះអង្គកំពុងធ្វើដំណើរតាមបឹងកាលីឡេ ព្រះយេស៊ូយាងទៅឯអ្នកនេសាទត្រីពីរនាក់។ ព្រះអង្គហៅពួកគេ និងមានបន្ទូលថា «ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឱ្យជាអ្នកនេសាទមនុស្សវិញ»។ ពួកគេបានចាកចោលការងាររបស់ពួកគេហើយទៅតាមព្រះអង្គ។ នៅថ្ងៃនោះព្រះយេស៊ូបានហៅសាវ័កបួននាក់ ដំបូងគឺពេត្រុស អនទ្រេយ៉ាកុប និងយ៉ូហាន ពួកគេទាំងអស់នោះជាអ្នកនេសាទ។

បន្ទាប់មកព្រះយេស៊ូបានយាងពាសពេញស្រុកកាលីឡេ បង្រៀននៅក្នុងព្រះវិហារ ប្រកាសពីដំណឹងល្អនៃនគរស្ថានសួគ៌ និងប្រោសជំងឺគ្រប់ប្រភេទឱ្យបានជាក្នុងចំណោមមនុស្សជាច្រើន។ មនុស្សជាច្រើនដើរតាមព្រះអង្គគ្រប់ទីកន្លែងនៅកន្លែងណាដែលព្រះអង្គទៅ។

មានមនុស្សឃ្លង់ម្នាក់បានចូលមកឯព្រះយេស៊ូ ហើយក៏ចាប់ផ្តើមថ្វាយបង្គំព្រះអង្គ។ គាត់បានហៅព្រះយេស៊ូហើយនិយាយថា «ឱព្រះអម្ចាស់អើយ បើព្រះអង្គសព្វព្រះហឫទ័យ ព្រះអង្គអាចនឹងប្រោសឱ្យទូលបង្គំជាស្អាតបាន» ព្រះអង្គមានបន្ទូលឆ្លើយថា *«ខ្ញុំចង់ដែរចូរឱ្យជាស្អាតចុះ»* ស្រាប់តែរោគឃ្លង់ក៏ជាស្អាតភ្លាម។

មានមេទ័ពរ៉ូម៉ាំងម្នាក់មកឯព្រះយេស៊ូ។ បុរសម្នាក់នេះចូលមកសុំឱ្យព្រះយេស៊ូប្រោសអ្នកបម្រើរបស់គាត់ដែលស្លាប់ដៃស្លាប់ជើង ដេកនៅផ្ទះវេទនាខ្លាំងណាស់។ គាត់ជឿលើអំណាចរបស់ព្រះយេស៊ូក្នុងការព្យាបាលជំងឺរបស់អ្នកបម្រើរបស់គាត់។ ព្រះយេស៊ូមានបន្ទូលប្រាប់គាត់ថា មានមនុស្សជាច្រើននៅគ្រប់ជាតិសាសន៍នឹងមកបរិភោគជុំគ្នានៅឯនគរស្ថានសួគ៌ និងអ្នកបម្រើបានជានៅពេលដូចគ្នាដែរ។

ក្រោយមក នៅត្រើយម្ខាងទៀតនៃបឹងមានបុរសពីរនាក់ដែលមានអារក្សចូល បុរសទាំងពីរនាក់នេះមានកម្លាំងខ្លាំង និងកាចសាហាវណាស់ គ្មាននរណាម្នាក់អាចចាប់ពួកគេបានឡើយ គ្មាននរណាម្នាក់អាចដើរកាត់តាមផ្លូវដែលពួកគេនៅនោះទេ។ ពួកគេរស់នៅតែក្នុងផ្នូរខ្មោចប៉ុណ្ណោះ។

នៅពេលពួកគេឃើញព្រះយេស៊ូ អារក្សបានស្រែកឡើងថា «តើយើងមានរឿងអ្វីនឹងលោក ឱព្រះយេស៊ូព្រះរាជបុត្រានៃព្រះជាម្ចាស់អើយ? តើព្រះអង្គយាងមកទីនេះនឹងដាក់ទោសយើងមុនពេលកំណត់ឬ?»។

ផ្លូវដ៏ល្អបំផុតដែលពួកគេទៅ គឺនៅក្នុងហ្វូងជ្រូក។ អារក្សបានអង្វរព្រះយេស៊ូថា «ប្រសិនជាព្រះអង្គដេញខ្ញុំចេញ សូមឱ្យពួកយើងចូលទៅក្នុងហ្វូងជ្រូកនោះទៅ» ព្រះយេស៊ូមានបន្ទូលទៅកាន់ពួកគេថា «ចេញទៅ»។ រំពេចនោះអារក្សបានចេញពីបុរសទាំងពីរនាក់នោះចូលទៅក្នុងហ្វូងជ្រូក ជ្រូកត្រូវអារក្សចូល និងផ្អើលរត់ចូលទៅក្នុងបឹងលង់ទឹកស្លាប់អស់ទៅ។

អ្នកចិញ្ចឹមជ្រូកបានរត់ទៅ និងប្រាប់អ្នកស្រុកនៅក្នុងក្រុងទាំងអស់ពីអ្វីដែលព្រះយេស៊ូបានធ្វើ រួមទាំងអ្វីដែលបានកើតឡើងចំពោះបុរសដែលមានអារក្សចូល។ ប្រជាជនបានចេញមកសុំឱ្យព្រះយេស៊ូចាកចេញពីកន្លែងរបស់ពួកគេ។

ព្រះយេស៊ូបានចាកចេញត្រលប់ទៅក្រុងរបស់ព្រះអង្គវិញ។ មិនយូរប៉ុន្មានព្រះអង្គបានជួបបុរសម្នាក់ឈ្មោះម៉ាថាយ។ ម៉ាថាយជាអ្នកទារពន្ធ ព្រះអង្គមានបន្ទូលមកកាន់គាត់ថា «ចូលមកតាមខ្ញុំ» រំពេចនោះម៉ាថាយក្រោកឡើងហើយដើរតាមព្រះយេស៊ូ។

ដូច្នេះ ព្រះយេស៊ូ និងសាវ័ករបស់ព្រះអង្គបានចេញទៅបរិភោគអាហារពេលល្ងាចជាមួយអ្នកទារពន្ធ និងមនុស្សដែលមានកេរ្តិ៍ឈ្មោះអាក្រក់ជាច្រើនទៀតនៅក្នុងក្រុង។ នៅពេលអ្នកកាន់សាសនាពួកអ្នកខាងគណៈផារិស៊ីបានឃើញនូវការនេះ ពួកគេសួរទៅកាន់សាវ័ករបស់ព្រះយេស៊ូថា «ហេតុអ្វីបានជាគ្រូរបស់អ្នកឯងទៅបរិភោគជាមួយនឹងអ្នកទារពន្ធ និងមនុស្សបាបដូច្នេះ?»។

ពេលព្រះយេស៊ូបានឮដូច្នេះ ព្រះអង្គបានឆ្លើយតបនឹងអាចារ្យផារិស៊ីថា «ពួកអ្នកដែលជាសុខសប្បាយមិនត្រូវការនឹងគ្រូពេទ្យទេ គឺជាពួកដែលមានជំងឺវិញទេតើ។ ប៉ុន្តែ ចូរយល់ពីពាក្យដែលថា «អញចង់បានសេចក្តីមេត្តាករុណាមិនមែនយញ្ញបូជាទេ» ពីព្រោះខ្ញុំមិនបានមកដើម្បីនឹងហៅមនុស្សសុចរិតទេ គឺមកហៅមនុស្សមានបាបឱ្យប្រែចិត្តវិញ។

## សំណួរផ្ទាល់មាត់

១. តើមុខរបររបស់ពួកសាវ័ករបស់ព្រះយេស៊ូដំបូងបំផុតគឺជាអ្វី?
២. តើពួកគេធ្វើអ្វីនៅពេលព្រះយេស៊ូបានហៅពួកគេឱ្យដើរតាមព្រះអង្គ?
៣. ព្រះយេស៊ូបានចេញទៅគ្រប់ទីកន្លែងនៃស្រុកកាលីឡេ និងហ្វូងមនុស្សបានដើរតាមព្រះអង្គ តើព្រះអង្គបានធ្វើអ្វីបានជាគេមានការចាប់អារម្មណ៍ដល់ព្រះអង្គ?
៤. តើការប្រោសឱ្យជាដំបូងបំផុតដែលបានកត់ទុកនៅក្នុងគម្ពីរម៉ាថាយគឺជាអ្វី?
៥. តើអ្នកបម្រើរបស់មេទាហានរ៉ូមមានបញ្ហាអ្វីកើតឡើង?
៦. តើបុរសពីរនាក់ត្រូវអារក្សចូលរស់នៅឯណា? ហើយតើបុរសទាំងពីរនាក់នេះជាមនុស្សប្រភេទណា?
៧. តើអារក្សបានធ្វើអ្វីនៅពេលពួកគេបានឃើញព្រះយេស៊ូ?
៨. តើមានអ្វីកើតឡើងចំពោះអារក្សនៅពេលពួកគេចេញពីបុរសទាំងនោះ?
៩. តើមានអ្វីកើតឡើងចំពោះហ្វូងជ្រូក?
១០.តើពួកអ្នកចិញ្ចឹមជ្រូកមានសកម្មភាពយ៉ាងដូចម្ដេច?
១១.តើបុរសឈ្មោះម៉ាថាយជាមនុស្សប្រភេទណា?
១២.តើព្រះយេស៊ូបានបរិភោគជាមួយនឹងមនុស្សប្រភេទណា?
១៣.តើពួកអ្នកខាងគណៈផារិស៊ីគិតយ៉ាងដូចម្ដេចចំពោះការនេះ?
១៤.តើចម្លើយរបៀបណាដែលព្រះយេស៊ូផ្ដល់ដល់អាចារ្យផារិស៊ី?

# មេរៀនទី៣

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ៤-៩

១. <u>ព្រះយេស៊ូមិនបានចែកព្រំខណ្ឌរវាងមនុស្ស និងមនុស្សទេ</u>

- ពួកសាវ័កដំបូងបំផុតរបស់ព្រះយេស៊ូជាអ្នកនេសាទត្រី ជាមនុស្សធម្មតាមិនបានទទួលការអប់រំឱ្យបានចេះដឹងជ្រៅជ្រះទេ។
- បុរសឃ្លង់គឺជាមនុស្សម្នាក់ដែលសង្គមមិនរាប់រកដោយសារតែជំងឺស្បែករបស់គាត់ដែលធ្វើឱ្យគាត់មានមុខមាត់អាក្រក់ និងគួរឱ្យខ្ពើម។
- អ្នកបម្រើមេទ័ពជនជាតិរ៉ូម៉ាំងជាមនុស្សខ្ញុំដែលគ្មានលុយឬមុខតំណែងនៅក្នុងសង្គមអ្វីឡើយ។
- ម៉ាថាយជាអ្នកទារពន្ធដារ ប្រហែលជាអ្នកមានបំផុត តែជាមនុស្សពុករលួយម្នាក់។
- បុរសអារក្សចូលពីរនាក់ត្រូវបានគេស្អប់ខ្ពើម។ តែមនុស្សម្នានៅក្នុងទីក្រុងនោះ ចង់ឱ្យជ្រូករបស់គេមានសុខភាពល្អ ជាងចង់ឱ្យបុរសទាំងពីរនាក់នោះបានជាសះស្បើយ ហើយបុរសទាំងពីរនាក់នោះរស់នៅតែក្នុងផ្នូរខ្មោចតែប៉ុណ្ណោះ។

*ប៉ុន្តែ មនុស្សទាំងនេះមានសារៈសំខាន់ ហើយមានតម្លៃសម្រាប់ព្រះយេស៊ូ។លោកអ្នកជាមនុស្សមានតម្លៃនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ អតីតកាលរបស់លោកអ្នក ប្រាក់កាក់របស់លោកអ្នករូបសម្បត្តិរបស់លោកអ្នក ឬទីកន្លែងរបស់លោកអ្នកនៅក្នុងសង្គមគ្មានន័យអ្វីសោះឡើយ សម្រាប់ព្រះអង្គ។

២. <u>ព្រះយេស៊ូមានគ្រប់ទាំងព្រះចេស្ដាដើម្បីប្រោសអស់ទាំងជំងឺ</u>

តើឧទាហរណ៍អ្វីនៅក្នុងរឿងនៃការប្រោសមនុស្សឱ្យជា?

៣. <u>ព្រះយេស៊ូមានគ្រប់ព្រះចេស្ដានឹងឈ្នះវិញ្ញាណអាក្រក់ និងអារក្សសាតាំង</u>

មានមនុស្សដែលបានក្លាយជាអ្នកដែលមានទំនាក់ទំនងជាមួយអារក្សសាតាំង ឬវិញ្ញាណអាក្រក់ ពួកគេតែងតែព្យាយាមធ្វើការល្អ។ ប៉ុន្តែ មុនពេលពួកគេដឹងថានឹងមានអ្វីកើតឡើងចំពោះពួកគេ នោះអារក្ស និងវិញ្ញាណអាក្រក់ទាំងនេះបានគ្រប់គ្រងលើជីវិតរបស់គេបាត់ទៅហើយ។ ពួកគេត្រូវធ្វើតាម និងទទួលការធ្វើបាបពីវិញ្ញាណអាក្រក់ទាំងនេះដោយមិនដែលទុកឱ្យពួកគេនៅតែម្នាក់ឯងទេ។ មនុស្សទាំងនេះគ្មានអំណាចអ្វីនឹងយកវិញ្ញាណអាក្រក់ចេញពីខ្លួនគេបានឡើយ។

**ព្រះយេស៊ូមានអំណាចឈ្នះវិញ្ញាណអាក្រក់ និងអារក្សនៅក្នុងលោកិយនេះបាន យើងអាចមានសេរីភាពពីវិញ្ញាណអាក្រក់តាមរយៈព្រះយេស៊ូតែមួយប៉ុណ្ណោះ។**

**៤. ព្រះយេស៊ូស្រឡាញ់មនុស្សដែលមានកេរ្តិ៍ឈ្មោះមិនល្អ ព្រះអង្គទទួលអស់អ្នកដែលមានបាប**

ព្រះយេស៊ូមិនបានកាត់ទោសមនុស្សនោះទេ ប៉ុន្តែ បំណងព្រះហឫទ័យរបស់ទ្រង់ គឺឱ្យមនុស្សទាំងអស់បានប្រែចិត្ត និងទទួលការអត់ទោសដ៏ពិតប្រាកដ។

**៥.** អ្នកដែលកាន់សាសនា ឬអ្នកខាងគណៈផារិស៊ីមិនបានលន់តួបាបរបស់ពួកគេទេ ហើយពួកគេគិតថា ពួកគេប្រសើរជាងមនុស្សមានបាបដទៃទៀតដែលបានបរិភោគអាហារជាមួយនឹងព្រះយេស៊ូទៅទៀត។ តើអ្វីទៅប្រសើរជាង? តើយើងព្រមធ្វើជាអ្នកមានអំពើបាបជាច្រើនដែលបានទទួលការអត់ទោស ឬក៏ជាមនុស្សមានបាបបន្តិចបន្តួចតែជាអ្នកបដិសេធ និងមិនព្រមប្រែចិត្ត?

**- វាល្អជាងឆ្ងាយណាស់ចំពោះការក្លាយជាមនុស្សមានអំពើបាបច្រើន តែបានទទួលការអត់ទោសនោះ។**

ព្រះយេស៊ូទទួល និងស្រឡាញ់យើងដូចដែលយើងក្នុងសភាពឥឡូវនេះ។ វាគ្មានបញ្ហាអ្វីទាំងអស់សម្រាប់ព្រះអង្គ ទោះបីយើងជាមនុស្សបាបយ៉ាងច្រើនក្រាស់ក្រែលយ៉ាងណាក៏ដោយ រៀនបានចេះដឹងតិច មានបញ្ហាច្រើន ឬមានជំងឺក៏ដោយ នៅក្នុងព្រះនេត្ររបស់ព្រះអង្គយើងទាំងអស់គ្នាដូចតែគ្នា ការសំខាន់មួយសម្រាប់យើងគឺត្រូវប្រែចិត្ត និងដើរតាមព្រះអង្គ។

# មេរៀនទី៤

# សេចក្តីបង្រៀនរបស់ព្រះយេស៊ូគ្រិស្ត

ម៉ាថាយ ១០-១៦

*«យើងមិនចង់បានយញ្ញបូជា គឺចង់បានតែចិត្តមេត្តាករុណាវិញ»*

*ម៉ាថាយ ១២:៧*

<u>វិញ្ញក</u>

១. ព្រះយេស៊ូបានប្រសូតជាមួយនឹងស្ត្រីសាសន៍យូដាឈ្មោះ____________។

២. ពួកព្យាការីមកពីតំបន់អាស៊ីអាចនឹងរកឃើញព្រះយេស៊ូ ព្រោះពួកគេដើរតាម____________។

៣. ពួកព្យាការីមិនបានត្រលប់ទៅវាំងរបស់ស្តេចហេរ៉ូឌវិញទេ ពីព្រោះព្រះជាម្ចាស់បានមានបន្ទូលទៅកាន់ពួកគេនៅក្នុង__________________ដើម្បីឱ្យត្រលប់ទៅផ្ទះរបស់គេវិញតាមផ្លូវផ្សេងវិញ។

៤. យ៉ូហានអ្នកធ្វើពិធីជ្រមុជទឹករស់នៅទីរហោស្ថានបង្រៀន និង__________ដល់អស់អ្នកដែលលន់តួបាបរបស់ពួកគេ។

៥. តើពាក្យថា «ប្រែចិត្ត» មានន័យយ៉ាងដូចម្តេច?

៦. នៅពេលព្រះយេស៊ូបានទទួលពិធីជ្រមុជទឹក________________យាងមកក្នុងសណ្ឋានដូចជាសត្វព្រាប និងមានសម្លេងនិយាយចេញមកពីស្ថានសួគ៌ការនេះបង្ហាញប្រាប់យើងពីបុគ្គលិកលក្ខណៈបីអង្គរបស់ព្រះជាម្ចាស់ដល់យើងគឺ៖______ _________និង__________________យើងហៅការនេះថា ព្រះត្រៃឯក។

៧. នៅទីរហោស្ថាន ព្រះយេស៊ូត្រូវបានទទួលសេចក្តីល្បួងដោយ__________

៨. សាវ័កដំបូងបំផុតរបស់ព្រះយេស៊ូជា__________________________

៩. ព្រះយេស៊ូបានដេញអារក្សឱ្យបុរសដែលមានអារក្សចូលពីរនាក់។

តើព្រះអង្គបានជួយពួកគេដោយរបៀបណា? តើប្រជាជនមានប្រតិកម្មតបព្រះយេស៊ូយ៉ាងណាដូចម្តេច?

១០.ពួកអ្នកខាងគណៈផារិស៊ីទិះតៀនព្រះយេស៊ូ ពីព្រោះព្រះអង្គបានបរិភោគជាមួយនឹងមនុស្សប្រភេទណា?

១១.តើវានឹងប្រសើរជាងឬអី ការដែលក្លាយជាមនុស្សដែលមានបាបយ៉ាងធ្ងន់ តែបានលន់តួ ឬក៏ជាមនុស្សមានបាបតែបន្តិចបន្តួចតែមិនមានចិត្តលន់តួនោះ?

ព្រះយេស៊ូបានហៅបុរស១២នាក់ដើម្បីធ្វើជាសាវ័ករបស់ព្រះអង្គ មានន័យជាពួកអ្នកដែលជិតស្និទ្ធនឹងព្រះអង្គ និងបង្ហឹកដោយព្រះអង្គផ្ទាល់។ ព្រះអង្គប្រទានដល់បុរសទាំង១២នាក់នេះនូវអំណាចឱ្យឈ្នះលើវិញ្ញាណអាក្រក់ និងព្រះអង្គប្រទានអំណាចដល់ពួកគេ ដើម្បីឱ្យប្រោសគ្រប់ជំងឺទាំងអស់។ ព្រះអង្គបានប្រាប់ដល់ពួកគេថា ពួកគេត្រូវតែឱ្យទៅអ្នកដទៃដោយឥតគិតថ្លៃដូចដែលពួកគេទទួលដោយឥតគិតថ្លៃដែរ ហើយយូដាស-អ៊ីស្ការីយ៉ុតនៅក្នុងចំណោមពួកគេផងដែរ ដែលត្រូវព្រះអង្គបានបញ្ជូនឱ្យចេញទៅនោះ។

ព្រះយេស៊ូបានបញ្ជូនពួកគេចេញទៅគ្រប់ទីកន្លែងនៃប្រទេសអ៊ីស្រាអែលដើម្បីហៅប្រជាជនយូដាឱ្យប្រែចិត្ត និងមានជំនឿលើព្រះយេស៊ូគ្រិស្ត។ ព្រះយេស៊ូបានប្រទានដល់បុរសទាំងនេះនូវសាររបស់ព្រះអង្គ «ដល់អស់អ្នកណាដែលទទួលស្គាល់ខ្ញុំចំពោះមនុស្ស នោះខ្ញុំនឹងទទួលស្គាល់អ្នកនោះចំពោះព្រះវរបិតាដែលគង់នៅស្ថានសួគ៌ផងដែរ។ ប៉ុន្តែ អស់អ្នកណាបដិសេធខ្ញុំចំពោះមុខមនុស្សនោះ ខ្ញុំនឹងបដិសេធអ្នកនោះនៅចំពោះព្រះភ័ក្រ្តព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ»។

ហើយព្រះយេស៊ូផ្ទាល់បានទៅគ្រប់ទីកន្លែងក្នុងស្រុកកាលីឡេ បង្រៀនចែកចាយដំណឹងល្អ និងព្យាបាលជំងឺគ្រប់ប្រភេទ។ ប៉ុន្តែ ប្រជាជននៅស្រុកកាលីឡេ គឺអស់អ្នកដែលព្រះយេស៊ូបានចំណាយពេលរបស់ព្រះអង្គជាច្រើនបានបដិសេធព្រះបន្ទូលរបស់ព្រះអង្គ។ ក្រុងកាពើណិមជាកន្លែងដែលព្រះអង្គបានចាប់ផ្ដើមកិច្ចការរបស់ព្រះអង្គជាសាធារណៈនៅទីនោះ ជាទីដែលបានបដិសេធទ្រង់ ហើយក្នុងការទតឃើញដូច្នោះ ព្រះយេស៊ូបានចេញទៅអធិស្ឋានទៅកាន់ព្រះវរបិតារបស់ព្រះអង្គ ហើយទាំងនេះជាព្រះបន្ទូលរបស់ព្រះអង្គ៖

«ឱព្រះវរបិតា ជាព្រះជាម្ចាស់នៃស្ថានសួគ៌ និងផែនដីអើយ ទូលបង្គំសរសើរព្រះអង្គ ដោយព្រោះព្រះអង្គលាក់សេចក្ដីទាំងនេះនឹងពួកអ្នកប្រាជ្ញ ហើយនឹងពួក

ឈ្លាសវៃ តែបានសម្ដែងឱ្យពួកកូនក្មេងយល់វិញ ហ្នឹងហើយព្រះវរបិតាអើយ ដ្បិតព្រះអង្គបានសព្វព្រះហឫទ័យយ៉ាងដូច្នោះ។ គ្រប់ទាំងសេចក្ដីទាំងអស់បានប្រគល់មកខ្ញុំពីព្រះវរបិតាខ្ញុំ ហើយគ្មានអ្នកណាស្គាល់ព្រះរាជបុត្រាទេ មានតែព្រះវរបិតាមួយ ក៏គ្មានអ្នកណាស្គាល់ព្រះវរបិតាដែរ មានតែព្រះរាជបុត្រា ហើយនិងអ្នកណាដែលព្រះរាជបុត្រាសព្វព្រះហឫទ័យចង់បើកឱ្យស្គាល់ព្រះអង្គផងប៉ុណ្ណោះ។

អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយចូរមកឯងខ្ញុំខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សម្រាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូតហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្ដីសម្រាកដល់ព្រលឹង ពីព្រោះនឹមខ្ញុំងាយទេហើយបន្ទុកខ្ញុំក៏ស្រាល»។

ក្រោយពីមានបន្ទូលពីការនេះ ព្រះយេស៊ូជាមួយនឹងសាវ័ករបស់ព្រះអង្គបានយាងកាត់វាលស្រែ ថ្ងៃនោះជាថ្ងៃឈប់សម្រាក។ សាវ័ករបស់ព្រះអង្គឃ្លានជាខ្លាំងដូច្នេះ ពួកគេឈប់បូតស្រូវសាឡីខ្លះហើយបរិភោគ។

ពួកអ្នកខាងគណៈផារិស៊ី (ពួកនេះជាអ្នកដឹកនាំសាសនា) ពួកគេឃើញដូច្នោះហើយ ក៏ចោទប្រកាន់ពួកសាវ័ក ពីព្រោះជាការប្រឆាំងនឹងច្បាប់នៃសាសន៍យូដាក្នុងការធ្វើការនៅថ្ងៃនេះ។ ព្រះយេស៊ូបានឆ្លើយតបទៅពួកគេវិញថាពួកគេនៅមិនទាន់យល់ពីច្បាប់របស់ព្រះជាម្ចាស់នៅឡើយទេ ពីព្រោះបទគម្ពីរបានចែងថា «យើងចង់បានសេចក្ដីមេត្តាករុណា មិនយញ្ញបូជាទេ»។

ព្រះយេស៊ូ និងសាវ័ករបស់ព្រះអង្គបានយាងចេញពីវាលស្រែនោះ ឆ្ពោះទៅសាលាប្រជុំរបស់សាសន៍យូដានៅទីនោះ ពួកគេបានជួបបុរសពិការដៃម្នាក់។ ព្រះយេស៊ូសួរបុរសនោះដើម្បីតម្រង់ដៃឱ្យគាត់វិញ ហើយព្រះអង្គបានប្រោសគាត់នៅទីនោះក្នុងសាលាប្រជុំនៅថ្ងៃឈប់សម្រាកនេះ។

ពួកអ្នកខាងគណៈផារិស៊ីបានខឹងសម្បាយ៉ាងខ្លាំងបានចាកចេញពីទីនោះដោយពិគ្រោះគ្នារកកលនឹងសម្លាប់ព្រះយេស៊ូ។ ព្រះយេស៊ូជ្រាបដឹងថាពួកគេរៀបគម្រោងកាណ៍ដើម្បីសម្លាប់ព្រះអង្គ ព្រះអង្គក៏ចាកចេញពីទីកន្លែងនោះទៅ។ ប៉ុន្តែ មនុស្សជាច្រើនបានដើរតាមព្រះអង្គព្រះអង្គបានប្រោសពួកគេទាំងអស់ឱ្យបានជា ប៉ុន្តែហាមពួកគេមិនឱ្យប្រាប់អ្នកដទៃ។

ព្រះយេស៊ូចាប់ផ្ដើមបន្តកិច្ចការរបស់ព្រះអង្គនៅក្នុងតំបន់នោះ ទាំងបង្រៀនមនុស្ស និងប្រោសជំងឺរបស់ពួកគេ។ ចំនួនមនុស្សទ្វេដងបានដើរតាមព្រះយេស៊ូចូល

ទៅក្នុងទីរហោស្ថាន ពួកគេស្នាក់នៅទីនោះយ៉ាងយូរដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះអង្គដោយមិនឃ្លានអ្វីសោះឡើយ។ ព្រះយេស៊ូបានយកនំបុ័ងតិចជាង៧ដុំ និងត្រី២-៣កន្ទុយ ព្រះអង្គបានចំអែតមនុស្ស៤ពាន់នាក់។

កាលព្រះអង្គនៅកំពុងធ្វើការនៅស្រុកកាលីឡេ ព្រះយេស៊ូបានពន្យល់យ៉ាងច្បាស់ថា ព្រះអង្គនឹងត្រូវទៅទីក្រុងយេរូសាឡិម ហើយការអាក្រក់ជាច្រើននឹងកើតឡើងនៅទីនោះ។ ព្រះអង្គមានបន្ទូលប្រាប់ពួកគេថា ព្រះអង្គនឹងទទួលការរងទុក្ខជាច្រើនក្នុងដៃនៃអ្នកដឹកនាំសាសនាយូដា ហើយព្រះអង្គនឹងត្រូវគេសម្លាប់ ប៉ុន្តែ បីថ្ងៃក្រោយព្រះអង្គនឹងរស់ពីការសោយទិវង្គតឡើងវិញ។

## សំណួរផ្ទាល់មាត់

១. តើការកិច្ចការអ្វីដែលព្រះយេស៊ូបានដាក់ឱ្យពួកសាវ័ករបស់ព្រះអង្គធ្វើ?

២. តើព្រះយេស៊ូមានបន្ទូលថា នឹងធ្វើអ្វីចំពោះអស់អ្នកដែលទទួលស្គាល់ព្រះអង្គនៅចំពោះមុខមនុស្ស ហើយនឹងធ្វើអ្វីចំពោះអស់អ្នកដែលបានបដិសេធព្រះអង្គចំពោះមុខមនុស្ស?

៣. តើប្រជាជននៅក្រុងកាពើណិម និងមនុស្សជាច្រើននៅស្រុកកាលីឡេជាកន្លែងដែលព្រះអង្គបានធ្វើការអស្ចារ្យដំបូងបំផុត មានប្រតិកម្មយ៉ាងដូចម្តេចខ្លះចំពោះព្រះរាជសាររបស់ព្រះយេស៊ូ?

៤. ព្រះយេស៊ូមានបន្ទូលដល់អស់អ្នកដែលមានបន្ទុកធ្ងន់ និងនឿយព្រួយថា ចូរឱ្យមកឯព្រះអង្គ តើព្រះអង្គមានព្រះបន្ទូលសន្យានឹងធ្វើអ្វីសម្រាប់មនុស្សអស់ទាំងនោះ?

៥. ហេតុអ្វីបានជាព្រះយេស៊ូ និងសាវ័ករបស់ព្រះអង្គឈប់នៅវាលស្រែ?

៦. ហេតុអ្វីបានជាពួកអ្នកខាងគណៈផារិស៊ីទិះតៀនព្រះយេស៊ូពីការបូតស្រូវសាឡីដូច្នេះ?

៧. ហេតុអ្វីបានជាពួកអ្នកខាងផារិស៊ីប្រឆាំងនឹងព្រះយេស៊ូក្នុងការប្រោសបុរសពិការដៃឱ្យជាដូច្នេះ?

៨. តើអ្នកដឹកនាំសាសនាមានគោលបំណងអ្វី?

៩. ព្រះយេស៊ូមានបន្ទូលប្រាប់អ្នកដែលដើរតាមព្រះអង្គថា ការជាច្រើននឹងកើតឡើងចំពោះព្រះអង្គជាប្រាកដ តើការប្រាប់ឱ្យដឹងជាមុនរបស់ព្រះអង្គនោះជាអ្វី?

## មេរៀនទី៤

# សេចក្ដីពិតខាងវិញ្ញាណ

ម៉ាថាយ ១០-១៦

១. អស់អ្នកដែលធ្វើបន្ទាល់ពីព្រះនាមព្រះយេស៊ូនៅចំពោះមុខមនុស្សព្រះអង្គនឹងធ្វើបន្ទាល់ពីអ្នកនោះនៅចំពោះមុខព្រះវរបិតារបស់ព្រះអង្គដែរ។ ប៉ុន្តែ អស់អ្នកណាបដិសេធព្រះអង្គនៅចំពោះមុខមនុស្សនោះព្រះអង្គនឹងបដិសេធន៍អ្នកនោះនៅមុខព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ។

២. មានមនុស្សជាច្រើនដើរតាមព្រះយេស៊ូ ពីព្រោះពួកគេចង់បានការអស្ចារ្យផ្សេងទៀតពីព្រះអង្គ ប៉ុន្តែ ពួកគេមិនចង់ធ្វើតាមព្រះបន្ទូលព្រះអង្គនោះទេ។ ពួកគេមិនចង់ប្រែចិត្តពីអំពើបាបរបស់ពួកគេទេ។ ពួកគេគ្រាន់តែចង់បានទទួលផលប្រយោជន៍ពីសេចក្ដីមេត្តាករុណារបស់ព្រះអង្គប៉ុណ្ណោះ។ តើសព្វថ្ងៃនេះនៅមានមនុស្សចូលចិត្តធ្វើនៅការនេះដែរឬទេ? លោកអ្នកស្គាល់មនុស្សប្រភេទនោះទេ?

៣. មានតែអ្នកដែលមកពីព្រះវរបិតាតែប៉ុណ្ណោះ គឺព្រះយេស៊ូគ្រិស្ត និងអស់អ្នកដែលបានចូលមកឯព្រះវរបិតាតាមរយៈព្រះយេស៊ូគ្រិស្តទេ។ គ្មានអ្នកកណ្ដាលណាផ្សេងទៀត ទេ ទៅ ដល់ ព្រះជាម្ចាស់ លើក លែង តែ ព្រះយេស៊ូ គ្រិស្ត មាន ព្រះ តែ មួយ អង្គប៉ុណ្ណោះ ហើយនឹងមានផ្លូវតែមួយប៉ុណ្ណោះ ហើយដែលព្រះគម្ពីរបង្រៀនថា មានផ្លូវតែមួយគត់ គឺព្រះយេស៊ូគ្រិស្ត។

*ប្រហែលជាលោកអ្នកធ្លាប់ត្រូវបានគេបង្រៀនឱ្យអធិស្ឋានទៅកាន់ព្រះជាម្ចាស់តាមអ្នកកណ្ដាលដែលផ្សេងពីព្រះយេស៊ូគ្រិស្ត។ តើអ្នកកណ្ដាលទាំងអស់នេះជាអ្នកណាពួកគេជាព្រះព្យាការី និងមនុស្សល្អពីមុនមក? ព្រះគម្ពីរចែងថាពួកគេប្រហែលជាមនុស្សល្អ ប៉ុន្តែ ពួកគេមិនមែនជាព្រះនោះទេ។ តើលោកអ្នកយល់ស្របជាមួយនឹងព្រះគម្ពីរដែរឬទេថា មានអ្នកកណ្ដាលតែម្នាក់ប៉ុណ្ណោះរវាងយើង និងព្រះជាម្ចាស់គឺព្រះយេស៊ូគ្រិស្ត?

៤. ព្រះយេស៊ូមានបំណងព្រះហឫទ័យទទួលយកបន្ទុក និងការនឿយព្រួយរបស់យើង ព្រះអង្គស្លូតហើយសុភាព ព្រះអង្គចង់បន្ធូរបន្ទុកនៅក្នុងចិត្តរបស់យើង។ ព្រះអង្គចង់រំដោះយើងចេញពីបន្ទុកដ៏ធ្ងន់ដែលយើងកំពុងតែស្ពាយ។ នៅក្នុងព្រះអង្គយើងអាចរកឃើញការសម្រាកខាងឯព្រលឹងប្រសិនជាយើងទទួលយកនឹមរបស់ព្រះអង្គ ន័យម្យ៉ាងទៀតប្រសិនជាយើងទទួលយកនូវការដឹកនាំរបស់ព្រះអង្គមកក្នុងជីវិតរបស់យើង។

៥. ព្រះយេស៊ូមានការយកចិត្តទុកដាក់នឹងសេចក្តីត្រូវការខាងឯសាច់ឈាមរបស់យើង។ ពួកសាវ័កកើតមានអំណត់ ហើយព្រះយេស៊ូបានប្រទាននូវចំណីអាហារសម្រាប់ពួកគេដោយទោះដឹងថា ការនេះនឹងត្រូវទទួលការទិះតៀន និងការបៀតបៀនពីសំណាក់ពួកអ្នកខាងគណៈផារិស៊ីក៏ដោយ។ ព្រះអាទិករនៃសាកលលោកទាំងមូលព្រួយបារម្ភអំពីសេចក្តីត្រូវការខាងឯសាច់ឈាមរបស់យើងម្នាក់ៗ។

«យើងចង់បានសេចក្តីមេត្តាករុណា មិនយញ្ញបូជាទេ» តើពាក្យថា «យញ្ញបូជា» មានន័យយ៉ាងដូចម្តេចចំពោះលោកអ្នក? តើលោកអ្នកទទួលការបង្រៀនពីអ្នកដឹកនាំសាសនាដើម្បីធ្វើយញ្ញបូជាសម្រាប់ព្រះជាម្ចាស់ ដើម្បីទទួលនូវការពេញចិត្តសម្រាប់ការអត់ទោសនៃអំពើបាបដែរឬទេ? តើវាមានការពិបាកណាស់ទៅឬសម្រាប់ឱ្យលោកអ្នកជឿថា ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងបង្ហាញនូវការអ្វីទាំងអស់ដល់ព្រះអង្គសម្រាប់យញ្ញបូជានោះ?

នេះជាលើកទីពីរហើយដែលព្រះយេស៊ូព្យាយាមពន្យល់ពួកអ្នកខាងគណៈផារិស៊ី ដែលព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងយញ្ញបូជារបស់មនុស្សនោះទេ។ ប៉ុន្តែសម្រាប់មនុស្សដែលជឿខាងសាសនា ការនេះជាញឹកញយវាតែងតែពិបាកនឹងទទួលយកណាស់។ គ្រប់ទាំងសាសនាទាំងអស់បង្រៀនថា យើងនឹងត្រូវធ្វើការខ្លះដើម្បីជៀសវាងសេចក្តីក្រោធរបស់ព្រះជាម្ចាស់ ឬបង្កើននូវការពេញចិត្តដល់ព្រះជាម្ចាស់។ មនុស្សជាច្រើនបានឆ្លងកាត់នូវការពិបាកជាច្រើន ដើម្បីព្យាយាមបង់ថ្លៃដល់ព្រះជាម្ចាស់វិញ សម្រាប់សេចក្តីសន្យាដែលគេបានចំណាយសម្រាប់អំពើបាបពីអតីតកាល ឬបង្ហាញពីការគោរពទៅដល់ព្រះជាម្ចាស់ នោះជាការសាមញ្ញ។ ប៉ុន្តែការទាំងនេះបង្ហាញថា **គ្មានតម្លៃ**ទាល់តែសោះសម្រាប់ព្រះជាម្ចាស់។ ព្រះអង្គចង់មានទំនាក់ទំនងជិតស្និទ្ធជាមួយយើងទាំងអស់គ្នា ព្រះអង្គបង្ហាញយើងសេចក្តីមេត្តាករុណាដល់យើង។ ព្រះអង្គមិនចង់បានយញ្ញបូជារបស់យើងនោះទេ។

ព្រះយេស៊ូដឹងថា ព្រះអង្គនឹងទទួលការឈឺចាប់គ្រប់យ៉ាង ហើយបន្ទាប់មក នឹងត្រូវសោយទិវង្គត ប៉ុន្តែបីថ្ងៃក្រោយមក ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញ។ នេះជាផ្នែកនៃគម្រោងការណ៍របស់ព្រះជាម្ចាស់។ព្រះអង្គបានព្យាយាមនឹងពន្យល់ការ នេះដល់សាវ័ករបស់ព្រះអង្គ ប៉ុន្តែពួកគេមិនបានយល់នូវការដែលថាហេតុអ្វីបានជា ព្រះអង្គត្រូវតែសោយទិវង្គត ហើយនឹងរស់ឡើងវិញនោះទេ។

*នៅក្នុងបីមេរៀនបន្ទាប់ខាងមុខនេះ យើងនឹងរៀនឱ្យយល់ពីសារៈសំខាន់នៃការ សោយទិវង្គត និងការរស់ឡើងវិញរបស់ព្រះយេស៊ូ ។ ព្រឹត្តិការណ៍តែមួយគ្មានពីរ នេះនឹងផ្លាស់ប្តូរប្រវត្តិសាស្ត្រពិភពលោករហូតតទៅ។ ព្រឹត្តិការណ៍នេះមានអំណាច នឹងកាច់បំបាក់នូវចំណងនៃអំពើបាប និងផ្លាស់ប្តូរជីវិតរបស់យើង។

# មេរៀនទី៥

# ការបញ្ជូនព្រះយេស៊ូ

ម៉ាថាយ ២០-២៦

«ឥឡូវនេះព្រះយេស៊ូកំពុងតែឡើងទៅក្រុងយេរូសាឡិម ព្រះអង្គយកសិស្ស ទាំង១២នាក់ទៅជាមួយដែរ។ នៅតាមផ្លូវព្រះអង្គមានបន្ទូលថា មើលយើងរាល់គ្នា ឡើងទៅក្រុងយេរូសាឡិម នោះកូនមនុស្សនឹងត្រូវបញ្ជូនទៅដល់ពួកសម្ដេចសង្ឃ និងពួកមេដឹកនាំសាសនា ដែលគេនឹងកាត់ទោសលោក និងដាក់ទោសដល់ជីវិត រួច នឹងបញ្ជូនទៅឱ្យពួកសាសន៍ដទៃ ឱ្យគេចំអកមើលងាយព្រមទាំងវាយនឹងរំពាត់ ហើយឆ្កាងលោក បីថ្ងៃក្រោយមកលោកនឹងមានជីវិតរស់ឡើងវិញ *«កាលព្រះយេស៊ូ កំពុងឡើងទៅក្រុងយេរូសាឡិម ព្រះអង្គនាំសាវ័កទាំងដប់ពីររូបទៅដាច់ដោយឡែក ពីគេ។ នៅតាមផ្លូវព្រះអង្គមានព្រះបន្ទូលទៅគេថា ឥឡូវនេះយើងឡើងទៅក្រុង យេរូសាឡិម។ បុត្រមនុស្សនឹងត្រូវគេបញ្ជូនទៅក្នុងកណ្ដាប់ដៃរបស់ពួកនាយកបូជា ចារ្យ និងពួកបណ្ឌិតខាងវិន័យ គេនឹងកាត់ទោសប្រហារជីវិតលោក។ គេនឹងបញ្ជូន លោកទៅក្នុងកណ្ដាប់ដៃរបស់សាសន៍ដទៃ ដើម្បីឱ្យពួកនោះចំអកដាក់លោក យក រំពាត់វាយលោក ព្រមទាំងឆ្កាងលោកទៀតផង ប៉ុន្តែបីថ្ងៃក្រោយមក លោកនឹងរស់ ឡើងវិញ»* ម៉ាថាយ ២០:១៧-១៩ ។

<u>រំឮក</u>

១. ព្រះយេស៊ូប្រសូតជាមួយនឹងស្ត្រីព្រហ្មចារីម្នាក់ឈ្មោះ_______________

២. ឪពុកព្រះយេស៊ូ_____________________________បានយល់សប្តិ ដែលព្រះជាម្ចាស់បានប្រាប់គាត់ឱ្យភៀសខ្លួនទៅប្រទេសអេស៊ីព្ទ ពីព្រោះស្ដេច ហេរ៉ូឌចង់_______________ព្រះយេស៊ូ។

៣. យ៉ូហានអ្នកធ្វើពិធីជ្រមុជទឹករស់នៅឯទីរហោស្ថានបង្រៀន និងធ្វើពិធីជ្រមុជ ទឹកដល់អស់ដែល_____________________ពីអំពើបាបរបស់ពួកគេ។

៤. ព្រះយេស៊ូមិនមាន_______________________ប៉ុន្តែ ព្រះអង្គបានសុំ

ឱ្យលោកយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក ធ្វើពិធីជ្រមុជទឹកឱ្យព្រះអង្គ។

៥. តើពាក្យថា «ប្រែចិត្ត» មានន័យយ៉ាងដូចម្ដេច?

៦. នៅពេលព្រះយេស៊ូបានទទួលពិធីជ្រមុជទឹក__________________បាន យាងមកសណ្ឋិតដូចជាសត្វព្រាប និងមានសម្លេងនៃព្រះជាម្ចាស់មកពីស្ថានសួគ៌ដោយមានបន្ទូលថា «នេះជា_________________________របស់អញជាទីពេញចិត្តយើងណាស់»។

៧. នៅទីរហោស្ថានព្រះយេស៊ូបានទទួលសេចក្ដីល្បួងដោយ____________។

៨. ព្រះយេស៊ូបានជួយបុរសពីរនាក់ដែលមាន______________________។ ព្រះយេស៊ូបានបង្ហាញថាព្រះអង្គមានអំណាចនឹង________វិញ្ញាណអាក្រក់។

៩. តើមួយណាល្អជាងសម្រាប់ការធ្វើជាមនុស្សមានបាបយ៉ាងច្រើនតែបានលន់តួឬក៏មានបាបតែបន្តិចបន្តួចតែមិនបានលន់តួនោះ?

១០. ព្រះយេស៊ូមានបន្ទូលថា ប្រសិនអ្នកណាទទួលព្រះអង្គនៅមុខមនុស្សលោក ព្រះអង្គ និងពីអ្នកនោះនៅមុខ_____________របស់ព្រះអង្គដែលគង់នៅឯស្ថានសួគ៌។

១១. ប្រជាជននៅក្នុងស្រុកកាលីឡេជាច្រើន រាប់បញ្ចូលទាំងមនុស្សដែលនៅស្រុកកាពើណិមទៀតផង__________________ព្រះបន្ទូលរបស់ព្រះ។ ពួកគេដើរតាមព្រះយេស៊ូដោយសារតែការអស្ចារ្យរបស់ព្រះអង្គបានធ្វើតែប៉ុណ្ណោះ។

១២. ពួកគេមិនចង់ប្រែចិត្តពីអំពើបាបរបស់ពួកគេនោះទេម្ដងទៀត តើពាក្យថា«ប្រែចិត្ត» មានន័យថាយ៉ាងដូចម្ដេច?

១៣. ព្រះយេស៊ូបានមានបន្ទូលថា ព្រះអង្គនឹងឱ្យ__________ដល់អស់អ្នកដែលមានបន្ទុកធ្ងន់ និងនឿយព្រួយសម្រាប់នឹមរបស់ព្រះអង្គគឺ____________។

១៤. ពួកអ្នកខាងគណៈផារិស៊ីមិនចង់ឱ្យព្រះយេស៊ូប្រោសបុរសពិការដៃនោះទេ ពីព្រោះវា នោះចំថ្ងៃ____________និងវាប្រឆាំងនឹងច្បាប់ក្នុងការធ្វើការនៅ________ផងដែរ។

១៥. អាចារ្យផារិស៊ីមានគម្រោងការណ៍នឹង__________________ព្រះយេស៊ូ។

១៦. ព្រះយេស៊ូបានដឹងពីគម្រោងការណ៍របស់អាចារ្យផារិស៊ី ប៉ុន្តែព្រះអង្គនៅតែធ្វើ

ការអស្ចារ្យជាច្រើន រាប់បញ្ចូលទាំងធ្វើឱ្យ________________ពិរកន្ទុយ និង ________ខ្លះដើម្បីចិញ្ចឹមមនុស្សច្រើនជាងបួនពាន់នាក់ទៀតផង។

ព្រះយេស៊ូជាមួយនឹងសាវ័ករបស់ព្រះអង្គបានធ្វើដំណើរពីស្រុកកាលីឡេទៅក្រុងយេរូសាឡឹម។ ព្រះយេស៊ូបានឱ្យសិស្សរបស់ព្រះអង្គពីរនាក់ទៅឯភូមិខាងមុខដើម្បីយកសត្វលាមួយដែលព្រះអង្គត្រូវការ។ ព្រះយេស៊ូបានអង្គុយនៅលើសត្វលានោះធ្វើដំណើរចូលទៅក្រុងយេរូសាឡឹម។

ព្រះអង្គបានយាងចូលទៅប្រកបដោយសិរីរុងរឿង និងជ័យជំនះ បណ្ដាជនប្រមូលគ្នាអមសងខាងព្រះអង្គ ហ្វូងមនុស្សបានក្រាលសម្លៀកបំពាក់របស់គេនៅលើផ្លូវ ដើម្បីធ្វើជាកម្រាលសម្រាប់ឱ្យព្រះយេស៊ូធ្វើដំណើរចូលទៅក្នុងទីក្រុង។ អ្នកខ្លះកាច់មែកឈើហើយក្រាលវានៅលើផ្លូវក្នុងន័យគោរពដល់ព្រះអង្គ ហើយអ្នកផ្សេងទៀតបានដើរពីមុខព្រះអង្គដោយស្រែកថា៖

*«ហូសាណាដល់ព្រះវង្សហ្លួងដាវីឌ ព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះអម្ចាស់ព្រះអង្គប្រកបដោយព្រះពរ ហូសាណានៅស្ថានសួគ៌ខ្ពស់បំផុត!»*

កាលព្រះអង្គយាងចូលទៅក្នុងទីក្រុងយេរូសាឡិមហើយ នោះក៏កើតមានសេចក្ដីជ្រួលជ្រើមពេញក្នុងទីក្រុង ហើយគេសួរថា«តើបុរសនេះជាអ្នកណា?» ហ្វូងមនុស្សឆ្លើយឡើងថា នេះគឺព្យាការីយេស៊ូដែលមកពីស្រុកណាសារ៉ែតនៃតំបន់កាលីឡេ។ ព្រះយេស៊ូបានចូលទៅក្នុងទីក្រុង ហើយចូលទៅក្នុងវិហារសាសន៍យូដា។ នៅទីនោះព្រះអង្គបានបណ្ដេញអស់ទាំងអ្នកលក់ដូរនៅក្នុងព្រះវិហារ ហើយនឹងផ្កាប់តុនៃពួកអ្នកដូរប្រាក់ដែលរៀបលក់ដូរនៅក្នុងព្រះវិហារ។ ដោយព្រះអង្គមានបន្ទូលថាមានសេចក្ដីចែងទុកមកថា «ដំណាក់អញត្រូវហៅថា ជាទីសម្រាប់អធិស្ឋានតែអ្នករាល់គ្នាបានយកធ្វើជារោងចោរវិញ» ក្រោយមកព្រះអង្គបានស្នាក់នៅក្នុងព្រះវិហារប្រោសមនុស្សខ្វាក់ និងមនុស្សខ្វិននៅទីនោះ។

ក្រោយពីព្រះយេស៊ូបានបង្រៀនមនុស្សពិការជាច្រើន និងបានធ្វើទីសំគាល់និងការអស្ចារ្យជាច្រើននៅក្នុងព្រះវិហារ រួចមកពួកសម្ដេចសង្ឃ និងអ្នកដឹកនាំសាសនាបានប្រជុំគ្នាដើម្បីសម្លាប់ព្រះយេស៊ូ។ ពួកគេបានពិភាក្សាគ្រប់ល្បិចកល្បដើម្បីសម្លាប់ព្រះអង្គ ពួកគេមានការអន្ទះអន្ទែងក្នុងការសម្លាប់ព្រះយេស៊ូណាស់នៅថ្ងៃបុណ្យរំលង។ ដូច្នេះ ពួកគេសម្រេចចិត្តរង់ចាំរហូតដល់ថ្ងៃបុណ្យរំលង ទើបសម្លាប់ព្រះអង្គ។

សិស្សម្នាក់ក្នុងចំណោមសិស្សទាំង១២នាក់ឈ្មោះយូដាស-អ៊ីស្ការីយ៉ុតបានចេញទៅឯសម្ដេចសង្ឃសួរថា «តើអ្នកនឹងឱ្យអ្វីមកខ្ញុំ ប្រសិនជាខ្ញុំបញ្ជូនព្រះយេស៊ូទៅឱ្យអ្នក?»។ ពួកគេយល់ព្រមនឹងឱ្យគាត់៣០កាក់។ ចាប់ពីថ្ងៃនោះមកយូដាសអ៊ីស្ការីយ៉ុតបានចាប់ផ្ដើមរកមើលឱកាស ដើម្បីនឹងបញ្ជូនព្រះយេស៊ូ។

នៅថ្ងៃបុណ្យរំលង ពួកសាវ័កបានរៀបចំអាហារពេលល្ងាចសម្រាប់ពិធីជប់លៀងទៅតាមអ្វីដែលព្រះយេស៊ូបានបង្គាប់។ នៅយប់នោះព្រះយេស៊ូអង្គុយជាមួយនឹងសាវ័ករបស់ព្រះអង្គទាំង១២នាក់ ហើយនិយាយទៅកាន់ពួកគេថា «ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ម្នាក់ក្នុងចំណោមអ្នករាល់គ្នានឹងបញ្ជូនខ្ញុំទៅ»។

កាលដែលព្រះអង្គមានបន្ទូលដូច្នេះ ពួកសាវ័កកើតមានការព្រួយបារម្ភយ៉ាងខ្លាំងពួកគេម្នាក់បានចាប់ផ្ដើមសួរកាន់ព្រះអង្គថា «ព្រះអម្ចាស់តើទូលបង្គំឬ?»។

ព្រះយេស៊ូបានឆ្លើយទៅកាន់ពួកគេថា «គឺជាអ្នកមួយដែលលូកដៃចុះក្នុងចានជាមួយនឹងខ្ញុំ អ្នកនោះឯងនឹងបញ្ជូនខ្ញុំទៅ។ ឯកូនមនុស្សត្រូវទៅមែនតាមសេចក្ដីដែលបានចែងទុកពីដំណើរលោក ប៉ុន្តែដល់អ្នកនោះដែលនឹងបញ្ជូនកូនមនុស្សទៅបើវាមិនបានកើតមកនោះល្អដល់វាជាជាង»។

យូដាសជាអ្នកដែលបញ្ជូនព្រះអង្គទៅ វាចាប់ពាក្យទូលថា លោកគ្រូអើយ តើខ្ញុំឬអី? ព្រះអង្គមានបន្ទូលទៅវាថា ត្រូវដូចអ្នកនិយាយហើយ។

នៅគ្រាដែលកំពុងបរិភោគនោះ ព្រះយេស៊ូបានយកនំបុ័ង កាលព្រះអង្គបានប្រទានពរនោះក៏កាច់ប្រទានទៅពួកសិស្សដោយបន្ទូលថា «នេះជារូបកាយខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះដើម្បីនឹករំលឹកដល់ខ្ញុំ»។ លុះជប់លៀងរួចហើយ ព្រះអង្គធ្វើបែបដដែល ព្រះអង្គយកពែងមកកាន់ទាំងមានបន្ទូលថា «នេះជាពែងនៃសម្ព័ន្ធមេត្រីថ្មី ចងឡើងដោយសារលោហិតរបស់ខ្ញុំ ដែលត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា»។ ក្រោយពីពួកគេបានទទួលទានហើយ ពួកគេបានច្រៀងទំនុកមួយហើយគេនាំគ្នាចេញទៅឯភ្នំដើមអូលីវ នៅទីនោះព្រះយេស៊ូចាប់ផ្ដើមបង្រៀនពួកគេនូវការជាច្រើនដែលនឹងកើតមានឡើងក្នុងពេលឆាប់ៗ។

បន្ទាប់មកព្រះយេស៊ូបាននាំពួកគេទៅដល់កន្លែងមួយដែលហៅថា «កេតសេម៉ានី» ជាកន្លែងដែលពួកគេធ្លាប់អធិស្ឋានជាមួយនឹងព្រះអង្គពេញមួយយប់។ ព្រះយេស៊ូបានយកពេត្រុស យ៉ាកុប និងយ៉ូហានទៅជាមួយនឹងព្រះអង្គ។ ព្រះអង្គចាប់ផ្ដើមមានព្រះហឫទ័យព្រួយ ហើយតប់ប្រមល់ជាខ្លាំង។ ព្រះអង្គក៏មានបន្ទូល

ឱ្យគេនៅចាំយាមជាមួយនឹងព្រះអង្គសិន កាលទ្រង់យាងទៅមុខបន្តិចដើម្បីនឹងអធិស្ឋានទៅកាន់ឯព្រះវរបិតាតែម្នាក់ឯង ព្រះអង្គបានអធិស្ឋាននៅយប់ដោយទទួលស្គាល់នូវការដែលនឹងត្រូវកើតឡើង។ ព្រះបន្ទូលរបស់ព្រះអង្គត្រូវបានកត់ទុកដូចខាងក្រោម៖

*ឱព្រះវរបិតានៃទូលបង្គំអើយ បើសិនជាបាននោះ សូមឱ្យពែងនេះកន្លងហួសពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយសូមតាមតែព្រះហឫទ័យរបស់ព្រះអង្គវិញ។*

វាត្រូវបានកត់ត្រាថា ព្រះអង្គអធិស្ឋានជារបៀបដូចនេះដដែលៗ៣ដង ហើយព្រះទ័យរបស់ព្រះអង្គមានការព្រួយយ៉ាងខ្លាំង។ ពួកសាវ័កមិនអាចចាំយាម សូម្បីតែមួយម៉ោងក៏មិនបានផង ពួកគេដេកលក់ទាំងអស់គ្នា។ ទីបំផុតព្រះយេស៊ូបានដាស់ពួកគេឡើងទាំងអស់គ្នាទាំងមានបន្ទូលថា «ចូរក្រោកឡើងយើងទៅ នុះន៎! អ្នកដែលបញ្ជូនខ្ញុំជិតមកដល់ហើយ»។

## សំណួរផ្ទាល់មាត់

១. តើព្រះយេស៊ូជិះលើសត្វអ្វីនៅពេលព្រះអង្គចូលទៅក្នុងក្រុងយេរូសាឡិម?

២. តើប្រជាជនធ្វើដាក់ព្រះយេស៊ូដោយរបៀបណានៅពេលព្រះអង្គកំពុងយាងចូលទៅ ក្នុងទីក្រុង?

៣. តើយូដាសបានធ្វើអ្វីដើម្បីក្បត់នឹងព្រះយេស៊ូ?

៤. តើពិធីបុណ្យអ្វីដែលគេកំពុងប្រារព្ធធ្វើនៅក្នុងក្រុង?

៥. តើព្រះយេស៊ូបានព្រមានយូដាសយ៉ាងម្តេច នៅពេលព្រះអង្គបានដឹងថា គាត់នឹងបញ្ជូនព្រះអង្គ?

៦. តើព្រះយេស៊ូមានបន្ទូលអំពីស្រានៅក្នុងការបរិភោគអាហារពេលយប់ថាជាអ្វី?

៧. ដោយយោងទៅតាមព្រះយេស៊ូមានបន្ទូល តើការបង្ហូរព្រះលោហិតមានសារៈសំខាន់ឬ?

៨. ព្រះយេស៊ូបានយកសាវ័ករបស់ព្រះអង្គ ទៅសួនច្បារកេតសេម៉ានីដើម្បីអធិស្ឋាននៅទីនោះពេញមួយយប់។ តើសាវ័កប៉ុន្មាននាក់ដែលអាចនៅអធិស្ឋានបាន នៅយប់នោះ?

៩. តើ សេចក្តី អធិស្ឋាន អ្វី ដែល ព្រះយេស៊ូ បាន អធិស្ឋាន នៅ យប់ ដែល គេ បញ្ជូន ព្រះអង្គ?

## មេរៀនទី៥

# សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ២០-២៦

១. ព្រះអម្ចាស់គ្រប់គ្រងលើអ្វីទាំងអស់។ ពួកអ្នកខាងគណៈផារិស៊ីមានគម្រោងការណ៍សម្លាប់ព្រះយេស៊ូ។ ព្រះជាម្ចាស់ប្រើពួកគេដើម្បីអនុវត្តន៍បំណងព្រះហឫទ័យដ៏ឥតខ្ចោះរបស់ព្រះអង្គនៅលើផែនដីគ្រប់ពេលទាំងអស់។ ជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលថា ព្រះយេស៊ូនឹងត្រូវសោយទិវង្គតនៅលើឈើឆ្កាង។

២. ព្រះជាម្ចាស់ដឹងពីអ្វីដែលមាននៅក្នុងចិត្តរបស់យើង តែអ្នកផ្សេងទៀតមិនដឹង ព្រះយេស៊ូជ្រាបគ្រប់ពេលទាំងអស់ដែលសាវ័ករបស់ផងព្រះអង្គយូដាសនឹងក្បត់ព្រះអង្គ។

៣. ព្រះយេស៊ូស្រឡាញ់យើង និងនៅតែស្រឡាញ់យើង ទោះបើយើងបដិសេធព្រះអង្គក៏ដោយ។ ព្រះយេស៊ូបានធ្វើចំពោះយូដាសដែលគ្មានសាវកណាមួយអាចនឹងជឿថាគាត់ជាអ្នកក្បត់នោះទេ។ ដូចគ្នាដែរព្រះយេស៊ូស្រឡាញ់យើង និងធ្វើចំពោះយើងដោយសេចក្តីស្រឡាញ់ ទោះបីជាច្រើនដងយើងក្បត់ និងបដិសេធព្រះអង្គក៏ដោយហើយព្រះអង្គមានផែនការសម្រាប់ជីវិតរបស់យើង។

៤. ព្រះលោហិតរបស់ព្រះយេស៊ូត្រូវបានហូរដើម្បីសំអាតអំពើបាបរបស់យើង។ ពួកសាវ័កមិនបានយល់ពីការពិតដែលថា ព្រះយេស៊ូត្រូវសោយទិវង្គតនោះទេ។ ពួកគេមិនបានយល់ទេថា ព្រះយេស៊ូបានសងថ្លៃឈ្នួលអំពើបាបនៅក្នុងជីវិតរបស់ពួកគេទេ ហើយការសងថ្លៃនេះគឺជាការបង្ហូរឈាម។ ពួកគេយល់ថា ព្រះយេស៊ូស្រឡាញ់ពួកគេ ហើយពួកគេបានទទួលការអត់ទោសចំពោះអំពើបាបរបស់គេ ។ ប៉ុន្តែ ពួកគេនឹងត្រូវការពេលជាច្រើនទៀតរហូតដល់ពួកគេយល់ពីតម្លៃដែលព្រះយេស៊ូបានចេញថ្លៃដើម្បីអត់ទោសអំពើបាបរបស់ពួកគេ។

* មនុស្សជាច្រើនដឹងថា ពួកគេមានអំពើបាបនៅក្នុងជីវិត។ អ្នកខ្លះប្រហែលជាធ្លាប់ឮអំពីរឿងរបស់ព្រះយេស៊ូ ជារឿងដែលព្រះអង្គស្រឡាញ់ពួកគេ។ ប៉ុន្តែមានមនុស្សតិចតួចណាស់ដែលយល់ថា ព្រះជាម្ចាស់បានបង្ហូរលោហិតសម្រាប់ជាថ្លៃលោះបាប។

ព្រះយេស៊ូជាព្រះ ហើយជាបុគ្គលតែម្នាក់គត់ដែលធ្លាប់មានព្រះជន្មគង់នៅឬនឹងគង់នៅលើផែនដីដោយគ្មានអំពើបាបទាល់តែសោះ។ ពីព្រោះព្រះអង្គជាព្រះដោយសារតែសេចក្តីស្រឡាញ់ដ៏លើសលប់របស់ព្រះអង្គសម្រាប់យើងព្រះអង្គបានជ្រើសរើសនឹងប្រគល់ជីវិតរបស់ព្រះអង្គជាយញ្ញបូជានឹងសងថ្លៃលោះបាបរបស់យើង។មិនគ្រាន់តែយើងប៉ុណ្ណោះទេ តែសម្រាប់អំពើបាបរបស់ពិភពលោកទាំងមូល។ គឺដោយសារតែដង្វាយបូជាយញ្ញនោះហើយ ដែលយើងឥឡូវមានឱកាសនឹងទទួលការអត់ទោសសម្រាប់អំពើបាប និងមានសន្តិភាពជាមួយព្រះជាម្ចាស់។

សប្តាហ៍ក្រោយយើងនឹងមើលឱ្យបានលំអិតពីការឆ្កាងរបស់ព្រះយេស៊ូ។

# មេរៀនទី៦

## ការឆ្កាងព្រះយេស៊ូ

ម៉ាថាយ ២៦-២៧

ព្រះយេស៊ូមានបន្ទូលទៅលោកថា *«ត្រូវដូចលោកមានប្រសាសន៍មែន ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ប្រាប់អស់លោកថា អំណេះតទៅអស់លោកនឹងឃើញបុត្រមនុស្ស គង់នៅខាងស្តាំព្រះដ៏មានឫទ្ធានុភាព ហើយនឹងយាងមកក្នុងពពកលើផ្ទៃមេឃ»*។ ម៉ាថាយ ២៦:៦៤

<u>រំឭក</u>

១. ព្រះយេស៊ូប្រសូតនឹងស្ត្រីព្រហ្មចារីម្នាក់ឈ្មោះ______________________។

២. ដូចដែលព្រះគម្ពីរបានថ្លែងទុក ព្រះយេស៊ូបានប្រសូតនៅភូមិ___________។

៣. ដូចដែលបទគម្ពីរបានចែង ព្រះយេស៊ូបានចេញទៅទឹកដីនៃ____________ពីព្រោះព្រះអង្គកំពុងគេចខ្លួនពីស្តេចហេរ៉ូឌ។

៤. ឪពុករបស់ព្រះយេស៊ូ______________បានយល់សប្តិឃើញថា ព្រះជាម្ចាស់បានឱ្យគាត់ត្រលប់ទៅប្រទេសអ៊ីស្រាអែលវិញ ពីព្រោះស្តេចហេរ៉ូឌបានសោយ-ទិវង្គតហើយ។ យ៉ូសែបនៅតែមានការភ័យខ្លាចចំពោះកូនរបស់ស្តេចហេរ៉ូឌ គាត់ក៏យកក្រុមគ្រួសាររបស់គាត់ទៅស្រុក________________ដែលមានភូមិមួយឈ្មោះថាណាសារ៉ែត។

៥. ព្រះយេស៊ូបានចាប់ផ្តើមកិច្ចការរបស់ព្រះអង្គ ដោយទទួលពិធីជ្រមុជទឹកដោយ__________________________________________________________។

៦. កាលព្រះយេស៊ូបានងើបចេញពីទឹកមកវិញ____________________មានសណ្ឋានដូចជាសត្វព្រាបមកពីស្ថានសួគ៌ និងមានសម្លេងនៃ________________និយាយពីស្ថានសួគ៌មកដោយបន្ទូលថា «នេះជាកូនស្ងួនភ្ងារបស់យើង ជាទីពេញ

ចិត្តយើងណាស់»។

៧. ព្រះយេស៊ូប្រោសមនុស្សជាច្រើន និងអត់ទោសដល់__________របស់ពួកគេ។

៨. ទោះជាមានការអស្ចារ្យច្រើនយ៉ាងណាក៏ដោយមនុស្សជាច្រើននៅតំបន់កាលីឡេ ______________________________សាររបស់ព្រះយេស៊ូ និងមិនប្រែចិត្តចង់លន់តួអំពើបាបគេទៀតផង។

៩. តើពាក្យថា «ប្រែចិត្ត លន់តួ» មានន័យយ៉ាងដូចម្ដេច?

១០. កាលព្រះយេស៊ូបានយាងចូលក្រុងយេរូសាឡិមមានក្បួនដង្ហែនៃមនុស្សជាច្រើនដែលហែរហមព្រះអង្គនៅក្នុងក្បួនដង្ហែ ព្រះយេស៊ូកំពុងអង្គុយនៅលើ__________។

១១. នៅថ្ងៃធ្វើពិធីបុណ្យរំលង ព្រះយេស៊ូបានប្រាប់សាវ័ករបស់ព្រះអង្គថា ម្នាក់ក្នុងចំណោមពួកគេនឹង____________________________ព្រះអង្គ។ នៅពេលនោះគ្មាននរណាម្នាក់ដឹងថា ម្នាក់នោះជាអ្នកណាទេ។

១២. ព្រះយេស៊ូមានបន្ទូលពីស្រាដែលពួកគេផឹកនោះ ព្រះអង្គមានបន្ទូលថា វាតំណាងឱ្យព្រះលោហិតរបស់ព្រះអង្គដែលនឹងបង្ហូរសម្រាប់________________អំពើបាប។

១៣. ពួកសាវ័កបានឮពាក្យទាំងនេះ ប៉ុន្តែ នៅតែមិនយល់ថា ព្រះយេស៊ូនឹងត្រូវ___ ______________________________________សម្រាប់អំពើបាបរបស់ពួកគេ។

១៤. ក្រោយពីអាហារពេលល្ងាចពួកគេបានចេញទៅឯភ្នំអូលីវ ហើយបន្ទាប់មកទៅឯសួនច្បារកេតសេម៉ានី ព្រះយេស៊ូបានអធិស្ឋាននៅយប់នោះ កាលពួកសាវ័ក_____ ______________។

១៥. ព្រះយេស៊ូអធិស្ឋានថា *«ប្រសិនជាអាចបានសូមឱ្យពែងនេះបានកន្លងផុតពីទូលបង្គំទៅ តែសូមកុំឱ្យទៅតាមបំណងចិត្តរបស់ទូលបង្គំឡើយតែឱ្យទៅតាមបំណងព្រះហឫទ័យរបស់*________________________________________*វិញ។*

កាលព្រះយេស៊ូកំពុងដាស់ពួកសាវ័ករបស់ព្រះអង្គ យូដាសជាម្នាក់ដែលក្បត់ព្រះអង្គបានមកដល់ជាមួយនឹងក្រុមមនុស្សរួមទាំងសម្ដេចសង្ឃ និងអ្នកដឹកនាំសាសនាបានយកទាំងដាវ និងលំពែងមកជាមួយផង។ យូដាសចូលទៅឯព្រះយេស៊ូ និងថើបព្រះអង្គដោយនិយាយថា «ជម្រាបសួរ លោកគ្រូ» ព្រះយេស៊ូបានឆ្លើយវិញថា*«សម្លាញ់ហេតុអ្វីបានជាឯងមក?»*។

រំពេចនោះសិស្សម្នាក់បានដកយកដាវចេញមក និងកាត់ស្លឹកត្រចៀកអ្នកបម្រើរបស់សម្ដេចសង្ឃម្នាក់។ ព្រះយេស៊ូបានឱ្យពួកសាវ័កនៅឱ្យស្ងៀម ហើយព្រះអង្គបានប្រោសត្រចៀករបស់បុរសម្នាក់នោះឱ្យជា។ ព្រះយេស៊ូមានបន្ទូលថាតើអ្នកស្មានថាខ្ញុំមិនអាចនឹងសូមដល់ព្រះវរបិតាខ្ញុំឥឡូវដែលព្រះអង្គនឹងចាត់ពួកទេវតា១២កងមកខ្ញុំជាមួយរំពេចទេឬអី បើយ៉ាងនោះធ្វើដូចម្ដេចនឹងបានសម្រេចតាមគម្ពីរដែលថា ត្រូវតែកើតមានដូច្នេះ។

បន្ទាប់មកព្រះយេស៊ូបានបែរទៅឯហ្វូងមនុស្សដែលបានមក និងសួរពួកគេថា *«តើអ្នករាល់គ្នាបានចេញមកចាប់ខ្ញុំដោយកាន់ដាវកាន់ដំបងដូចជាមកចាប់ចោរឬអី ខ្ញុំបានអង្គុយជាមួយនឹងអ្នករាល់គ្នា ហើយបង្រៀននៅក្នុងព្រះវិហាររាល់ថ្ងៃតែអ្នករាល់មិនបានចាប់ខ្ញុំទេ ប៉ុន្តែការទាំងនេះបានកើតមកដើម្បីឱ្យបានសម្រេចតាមទំនាយពួកព្យាការីវិញ»*។

នោះពួកសិស្សទាំងអស់ក៏រត់ចោលព្រះអង្គទុកឱ្យព្រះអង្គនៅតែម្នាក់ឯង។ ពួកអ្នកដែលបានចាប់ព្រះយេស៊ូគេដឹកនាំព្រះអង្គទៅឯលោកកៃផាជាសម្ដេចសង្ឃ នៅសម័យនោះនៅកន្លែងដែលពួកមេដឹកនាំសាសនា និងពួកចាស់ទុំសួរចម្លើយព្រះអង្គ។

ពួកគេបានរៀបចំសេចក្ដីបន្ទាល់ក្លែងទាស់នឹងព្រះយេស៊ូប្រយោជន៍ឱ្យបានសម្លាប់ព្រះអង្គ ប៉ុន្តែ ទោះបើមានស្មរបន្ទាល់ក្លែងក្លាយមកជាច្រើននាក់ក៏ដោយគង់តែរកមិនបានសោះរហូតដល់សម្ដេចសង្ឃមកសួរចម្លើយព្រះអង្គ ទីបំផុតគាត់សួរព្រះយេស៊ូថា «ចូរស្បថនឹងព្រះដែលមានព្រះជន្មរស់ចុះ បើអ្នកជាព្រះគ្រិស្តជាព្រះរាជបុត្រាមែន»។

ព្រះយេស៊ូមានបន្ទូលទៅគាត់វិញថា «ត្រូវដូចលោកមានប្រសាសន៍ហើយមួយទៀតខ្ញុំប្រាប់អ្នករាល់គ្នាថា អំណេះទៅមុខ អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយនៅខាងស្ដាំនៃព្រះដ៏មានព្រះចេស្ដា ហើយទាំងមកលើពពកនៅលើមេឃផង»។

ក្រោយពីបានស្ដាប់ពុចម្លើយនោះហើយ នោះសម្ដេចសង្ឃក៏ហែកអាវខ្លួនហើយនិយាយឡើងថា «វាប្រមាថដល់ព្រះហើយ!»។ មនុស្សម្នាដែលនៅជុំវិញនោះបានយកព្រះយេស៊ូចេញទៅក្រៅ ហើយចាប់ផ្ដើមស្ដោះទឹកមាត់ដាក់ព្រះភក្ត្រព្រះអង្គ។មានអ្នកខ្លះដាល់ព្រះអង្គនៅពេលដែលពួកគេបានយកដៃរបស់គេទះព្រះអង្គទាំងនិយាយថា «ចូរទាយប្រាប់យើងចុះព្រះគ្រិស្តអើយ តើអ្នកណាបានវាយឯង»។

ពេលព្រឹកបានមកដល់សម្តេចសង្ឃ និងពួកអ្នកដឹកនាំសាសនាបានយកព្រះយេស៊ូទៅឯមន្ត្រីរ៉ូម៉ាំងម្នាក់ដែលកាន់កាប់នៅតំបន់នោះឈ្មោះប៉ុនទាស-ពីឡាត ពួកគេបានប្រាប់គាត់ថា ព្រះអង្គបានអះអាងខ្លួនជាស្តេចនៃជនជាតិយូដា។

លោកពីឡាតបានយកព្រះអង្គទៅ និងសួរចម្លើយព្រះអង្គដោយសួរថា «តើឯងជាស្តេចនៃសាសន៍យូដាឬ? ព្រះយេស៊ូបានឆ្លើយតបវិញថា «ត្រូវដូចលោកមានប្រសាសន៍ហើយ»។

ប៉ុន្តែ ក្រោយពីការសួរចម្លើយរបស់គាត់រួចហើយពីឡាតមិនអាចរកឃើញហេតុផលនឹងឆ្កាងព្រះយេស៊ូបានឡើយ។ ជាមួយគ្នានេះដែរប្រពន្ធរបស់គាត់បានប្រាប់សុបិនពេញមួយយប់មុនថ្ងៃនោះ ហើយគាត់បានប្រាប់ប្តីរបស់គាត់កុំឱ្យធ្វើអ្វីទាំងអស់ជាមួយនឹងព្រះយេស៊ូ។ លោកពីឡាត់ដឹងថាអ្នកដឹកនាំសាសន៍យូដាគ្រាន់តែចង់ប្រគល់ព្រះយេស៊ូទៅគាត់ ដោយព្រោះចំពោះការច្រណែនប៉ុណ្ណោះ។ ប៉ុន្តែគាត់មិនដឹងថាអ្វីនឹងត្រូវធ្វើសម្រាប់មនុស្សដែលកំពុងជ្រួលច្របល់នោះឡើយ។

ជារៀងរាល់ឆ្នាំនៅថ្ងៃបុណ្យរំលង វាជាទម្លាប់របស់លោកពីឡាត ក្នុងការដោះលែងអ្នកទោសម្នាក់ ទៅតាមជាការជ្រើសរើសរបស់ប្រជាជន។ ហើយនៅឆ្នាំនេះមានអ្នកទោសដ៏ល្បីឈ្មោះម្នាក់នៅក្នុងគុកឈ្មោះបារ៉ាបាស។ ដូច្នេះគាត់មានបារ៉ាបាស និងព្រះយេស៊ូនឹងធ្វើការប្រគល់ដល់ប្រជាជន «តើមួយណាដែលអ្នករាល់គ្នាចង់ឱ្យខ្ញុំដោះលែង តើបារ៉ាបាស ឬយេស៊ូដែលហៅថាព្រះគិស្តនោះ?។ ប៉ុន្តែមនុស្សម្នាក់ដែលនៅខាងអ្នកខាងគណៈផារិស៊ីបានស្រែកឡើងថា «បារ៉ាបាស»។

លោកស្រែកពីឡាតសួរប្រជាជនថា «តើឱ្យខ្ញុំធ្វើនឹងយេស៊ូ ដែលហៅថាព្រះគ្រិស្តដោយរបៀបណា?» ប្រជាជនស្រែកឡើងថា «ឆ្កាងវាទៅ»។

ដូច្នេះដោយឃើញប្រជាជនកំពុងចាប់ផ្តើមបះបោរ លោកពីឡាតក៏យកទឹកមកលាងដៃដោយនិយាយថា «ខ្ញុំគ្មានទោសនឹងឈាមនៃអ្នកសុចរិតនេះទេ ការនេះស្រេចនៅអ្នករាល់គ្នាចុះ»។ បន្ទាប់មកគាត់ក៏ដោះលែងបារ៉ាបាសទៅឱ្យប្រជាជននិងប្រគល់ព្រះយេស៊ូទៅឱ្យគេវាយ។

ទាហានរបស់លោកពីឡាតបានយកព្រះយេស៊ូទៅកន្លែងរបស់លោកពីឡាតនៅទីនោះពួកគេធ្វើបាប និងចំអកឱ្យព្រះអង្គ។ ពួកគេប្រមូលគ្នាមកជុំវិញព្រះអង្គវាយព្រះអង្គនឹងរំពាត់ និងយកអាវក្រហមមកបំពាក់ឱ្យព្រះអង្គ។ បន្ទាប់មកពួកគេក្រងភួងបន្លាបំពាក់លើព្រះសិរព្រះអង្គ។ ពួកគេបានយកដើមត្រែងមកដាក់លើព្រះ

ហាស្ដស្ដាំព្រះអង្គរួចគេលុតជង្គង់នៅចំពោះព្រះអង្គ ទាំងពោលចំអកថា «សូមក្រាបថ្វាយបង្គំស្ដេចសាសន៍យូដា»។ គេស្ដោះទឹកមាត់ដាក់ព្រះអង្គ និងយកដើមត្រែងនោះវាយព្រះសិរបស់ព្រះអង្គផង។ ក្រោយពីបញ្ចប់ការចំអកឡកឡឺយដល់ព្រះអង្គរួចហើយ ពួកគេបានដោះអាវចេញ ហើយបំពាក់សម្លៀកបំពាក់របស់ព្រះអង្គឱ្យព្រះអង្គវិញ និងយកព្រះអង្គទៅកន្លែងមួយដែលហៅថា **គាល់កូថា**ដែលប្រែថា**ភ្នំលលាដ៍ក្បាល** ជាកន្លែងដែលព្រះអង្គត្រូវគេឆ្កាង។

ព្រះយេស៊ូបានឆ្កាងនៅទីនោះ ហើយនៅលើឈើឆ្កាងទាហានរ៉ូម៉ាំងបានដាក់ស្លាកពីលើព្រះសិរព្រះអង្គថា «នេះឈ្មោះយេស៊ូជាស្ដេចសាសន៍យូដា» ព្រះយេស៊ូបានឆ្កាងនៅចន្លោះចោរពីរនាក់ មួយខាងឆ្វេង និងមួយទៀតនៅខាងស្ដាំ។

ចាប់ពីម៉ោងប្រហែលជា៦ទៅដល់ម៉ោងទី៩ ព្រះយេស៊ូបានជាប់នៅលើឈើឆ្កាង។ នៅពេលនោះភាពងងឹតបានគ្របពេញលើផែនដីហើយប្រហែលជាម៉ោងទី៩ ព្រះយេស៊ូបន្លឺសម្លេងឡើងថា «**អេលីៗល៉ាម៉ាសាបាច់ថានី?**» ដែលប្រែថា «**ឱព្រះជាម្ចាស់ ព្រះជាម្ចាស់នៃទូលបង្គំអើយ ហេតុអ្វីបានព្រះអង្គចោលទូលបង្គំ**» មិនយូរប៉ុន្មានទ្រង់បន្លឺសម្លេងឡើងម្ដងទៀតថា «ព្រះបិតាអើយ! ទូលបង្គំសូមប្រគល់វិញ្ញាណរបស់ទូលបង្គំនៅក្នុងព្រះហស្ដព្រះអង្គវិញ»។

នៅពេលនោះព្រះអង្គបានប្រគល់វិញ្ញាណរបស់ព្រះអង្គទៅវិញ ហេតុការណ៍ដែលមិនអាចនឹងពិពណ៌នាបានជាច្រើនបានកើតឡើងក្នុងពេលតែមួយ។ វាំងននក្នុងព្រះវិហារក៏រហែកជាពីរភាគ ចាប់តាំងពីលើចុះមកដល់ក្រោម។ ក៏មានកក្រើកដីហើយប្រេះដាច់ពីគ្នាអស់ទាំងផ្នូរខ្មោចក៏របើកឡើង។ ឯខ្មោចពួកអ្នកបរិសុទ្ធដែលដេកលក់ទៅហើយ បានរស់ឡើងវិញជាច្រើន។ ទាំងចេញពីផ្នូរក្នុងពេលក្រោយដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ហើយចូលទៅក្នុងទីក្រុងយេរូសាឡិមលេចមកឱ្យមនុស្សជាច្រើនឃើញដែរ។

## សំណួរផ្ទាល់មាត់

១. តើព្រះយេស៊ូត្រូវបានបញ្ជូនដោយរបៀបណា?

២. សាវ័កម្នាក់របស់ព្រះយេស៊ូបានធ្វើការមួយក្នុងបំណងនឹងការពារព្រះយេស៊ូ តើគាត់បានធ្វើអ្វី ហើយតើព្រះយេស៊ូមានប្រតិកម្មយ៉ាងដូចម្ដេច?

៣. នៅក្នុងពេលដែលព្រះយេស៊ូត្រូវបានគេបញ្ជូន តើសាវ័ករបស់ព្រះអង្គបានធ្វើអ្វី?

៤. តើពួកគេបានចាប់ព្រះយេស៊ូចេញពីសួនច្បារយកទៅឯណា? តើពួកទាហានបានចាប់យកព្រះយេស៊ូពីសួនច្បារទៅឯណា?

៥. ទោះបីជាមានស្មរបន្ទាល់ក្លែងក្លាយជាច្រើន តើពួកគេចោទព្រះយេស៊ូដោយរបៀបណា?

៦. តើអ្នកដឹកនាំសាសន៍យូដាបានយកព្រះយេស៊ូទៅណានៅពេលដែលពេលព្រឹកបានកន្លងផុតទៅ?

៧. ក្រោយពីសួរចម្លើយរួច លោកពីឡាតមិនបានរកឃើញនូវកំហុសណាមួយនៅក្នុងព្រះយេស៊ូសោះ ប៉ុន្តែដោយសារគាត់មានសេចក្ដីភ័យខ្លាចចំពោះប្រជាជន គាត់ក៏ឱ្យឱកាសមួយប្រជាជន តើអ្វីដែល លោក ពីឡាត បាន ឱ្យ ទៅ ពួក គេ ហើយតើ ពួកគេជ្រើសរើសយកអ្វី?

៨. តើពួកទាហានធ្វើយ៉ាងដូចម្ដេចខ្លះចំពោះព្រះយេស៊ូ?

៩. ក្រោយ ពី មាន មេឃ ងងឹត រយៈ ពេល ៣ ម៉ោង ព្រះយេស៊ូ បាន បន្លឺ សម្លេង ទៅ ឯ ព្រះជាម្ចាស់ តើឃ្លាដែលព្រះយេស៊ូមានបន្ទូលនោះបកប្រែថាដូចម្ដេច?

១០.តើមានការអ្វីខ្លះបានកើតឡើងនៅពេលព្រះយេស៊ូបានប្រគល់វិញ្ញាណរបស់ព្រះអង្គទៅនោះ?

## មេរៀនទី៦

# សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ ២៦-២៧

១. តើព្រះយេស៊ូជាអ្នកណា? «ជាព្រះរាជបុត្រានៃព្រះជាម្ចាស់ អង្គុយនៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយនឹងយាងមកពីលើពពកនៃស្ថានសួគ៌»។ នេះជាចម្លើយដែលព្រះយេស៊ូឱ្យទៅសម្តេចសង្ឃ ហើយដោយការឆ្លើយតបនេះហើយដែលធ្វើឱ្យគេយកព្រះអង្គទៅឆ្កាង។ វាគឺជាចម្លើយដែលមនុស្សទាំងនោះមិនអាចទទួលយកបាន។ ប៉ុន្តែមនុស្សម្នាក់ៗត្រូវតែប្រឈមមុខនឹងសំណួរនេះដូចគ្នាដែរ។ តើព្រះយេស៊ូជាអ្នកណាឱ្យប្រាកដទៅ? ពីព្រោះប្រសិនជាព្រះយេស៊ូពិតជាអង្គុយនៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយយាងមកពីលើពពកនៃស្ថានសួគ៌មែននោះ តើយើងត្រូវសម្រេចចិត្តនឹងឆ្លើយតបទៅព្រះអង្គវិញដោយរបៀបណា?។

២. ព្រះយេស៊ូបានជាប់ឆ្កាងជំនួសកន្លែងបារ៉ាបាសជាអ្នកទោសឧក្រិដ្ឋដ៏កាចសាហាវ ហើយបារ៉ាបាសបានទទួលសេរីភាព។

*ប្រហែលជាខ្ញុំមិនមែនជាឧក្រិដ្ឋជនដ៏កាចសាហាវនោះទេ ប៉ុន្តែ គ្រាន់តែដូចជាបារ៉ាបាស ខ្ញុំជាមនុស្សមានបាប ហើយនៅចំពោះមុខព្រះជាម្ចាស់ ខ្ញុំក៏ត្រូវទទួលឈ្នួលនៃសេចក្តីស្លាប់ផងដែរ។ នៅក្នុងព្រះគម្ពីររ៉ូម៦:២៣ចែងថា «ឈ្នួលនៃអំពើបាបជាសេចក្តីស្លាប់» នេះមានន័យថា យើងសមនឹងស្លាប់ដោយសារតែការអាក្រក់ជាច្រើនដែលយើងបានធ្វើនៅក្នុងជីវិតរបស់យើង។ វាមិនមែនជាបញ្ហានោះ ប្រសិនជាយើងប្រព្រឹត្តអំពើបាបច្រើនករណីដូចជាបារ៉ាបាស ឬប្រសិនជាយើងជាមនុស្សល្អដូចជាសាវ័ករបស់ព្រះយេស៊ូនោះ។

៣. ព្រះយេស៊ូត្រូវបានគេធ្វើបាបកាត់ទោស និងសម្លាប់ដើម្បីសងថ្លៃនៃអំពើបាបដែលមាននៅក្នុងជីវិតរបស់យើង។ នេះគឺជាហេតុផលដែលព្រះយេស៊ូយាងមកលើផែនដី។ ព្រះអង្គចង់ឱ្យយើងអាចនឹងឈរនៅចំពោះព្រះភក្ត្រព្រះវរបិតាដើម្បីទទួលការអត់ទោសបាប ។ អ្នកខ្លះនិយាយថាព្រះយេស៊ូជាអ្នកដ៏អស្ចារ្យបានស្លាប់ដើម្បី

សាសន៍របស់ព្រះអង្គ និងជាព្យាការី។ ប៉ុន្តែ នេះមិនមែនជាការពិតនោះទេ ដោយយោងទៅតាមការទទួលសារភាពផ្ទាល់របស់ព្រះយេស៊ូ ព្រះអង្គបានអះអាងថា ព្រះអង្គជាព្រះ ហើយយាងមកផែនដីដើម្បីសោយទិវង្គតសម្រាប់អំពើបាបរបស់យើង។

៤. ព្រះយេស៊ូបានប្រគល់វិញ្ញាណរបស់ព្រះអង្គទៅវិញ។ ព្រះយេស៊ូអាចនឹងចុះពីលើឈើឆ្កាងមកនៅពេលណាក៏បានដែរ ។ ព្រះអង្គអាចនឹងសម្លាប់អស់អ្នកដែលសើចចំអកដល់ព្រះអង្គដោយគ្រាន់តែប្រើព្រះបន្ទូលក៏បាន។ ប៉ុន្តែ ទៅតាមការជ្រើសរើសរបស់ព្រះអង្គទ្រង់ទ្រាំទ្រដោយបន្ទាបខ្លួន ទ្រាំនៅលើឈើឆ្កាងរហូតដល់ម៉ោងកំណត់បន្ទាប់មកនៅក្នុងពេលរបស់ព្រះអង្គ ព្រះអង្គបានប្រគល់វិញ្ញាណរបស់ព្រះអង្គទៅវិញ ។ព្រះអង្គជ្រើសរើសនឹងសោយទិវង្គត ពីព្រោះព្រះអង្គចង់សងថ្លៃឈ្នួលនៃអំពើបាបរបស់យើងទាំងអស់គ្នា ព្រះគម្ពីរយ៉ូហាន៣:១៦ចែងថា «ដ្បិតព្រះព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកដល់ម្លេះ បានជាព្រះអង្គប្រទានព្រះរាជបុត្រាតែមួយ ដើម្បីឱ្យអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះនឹងមិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ»។

*នៅមេរៀនបន្ទាប់យើងនឹងរៀនពីការរស់ឡើងវិញរបស់ព្រះយេស៊ូ។ សេចក្តីពិតគឺព្រះយេស៊ូមិនបានសោយទិវង្គតរហូតទេ ប៉ុន្តែ ព្រះអង្គនៅមានជន្មគង់នៅ ហើយសព្វថ្ងៃនេះ ព្រះអង្គចង់មកគង់ក្នុងជីវិតរបស់លោកអ្នក ។ ព្រះអង្គចង់សំអាតចិត្តរបស់លោកអ្នកពីអំពើបាបទាំងអស់ ហើយបំផ្លាស់បំប្រែជីវិតរបស់លោកអ្នក។

# មេរៀនទី៧
# ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ

ម៉ាថាយ ២៧-២៨

*«កុំឱ្យភ័យអី ដ្បិតខ្ញុំដឹងហើយថា នាងមករកព្រះយេស៊ូដែលត្រូវឆ្កាងតែព្រះអង្គមិនបានគង់នៅទីនេះទេ ដ្បិតព្រះអង្គមានព្រះជន្មរស់ឡើងវិញហើយ ដូចជាទ្រង់បានមានបន្ទូលទុក»។* *ម៉ាថាយ ២៨:៥-៦*

<u>រំឭក</u>

១. ព្រះយេស៊ូប្រសូត្រពីនាងព្រហ្មចារីម្នាក់ឈ្មោះ____________________

២. ព្រះយេស៊ូបានចាប់ផ្ដើមកិច្ចការរបស់ព្រះអង្គបានធ្វើ______________ពីបុរសម្នាក់ឈ្មោះយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក។

៣. នៅក្នុងពិធីជ្រមុជទឹករបស់ព្រះអង្គ_______________យាងមកសណ្ឋិតលើព្រះអង្គដូច ជាសត្វព្រាប ហើយមានសម្លេងនិយាយពីស្ថានសួគ៌មកដោយបន្ទូលថា «នេះជា __________ សួនភ្ងារបស់យើង ជាទីពេញចិត្តយើងណាស់»។ ការនេះ បង្ហាញយើងនូវតួអង្គបីអង្គនៃព្រះត្រៃឯក ព្រះ______________ ព្រះ______________និងព្រះ______________។

៤. ព្រះយេស៊ូបានប្រោសជំងឺមនុស្សជាច្រើនឱ្យបានជា និងអត់ទោសដល់មនុស្សជាច្រើននូវ________________________របស់ពួកគេ។

៥. ក្រោយពីមានការអស្ចារ្យជាច្រើនមនុស្សជាច្រើនដែលរស់នៅក្នុងស្រុកកាលីឡេបានបដិសេធព្រះបន្ទូលរបស់ព្រះអង្គ និងមិនចង់______________អំពើបាបរបស់ពួកគេនោះទេ។

៦. តើពាក្យថា «លន់តួ» មានន័យយ៉ាងដូចម្ដេច?

៧. ព្រះយេស៊ូមានបន្ទូលថា ស្រាតំណាងឱ្យឈាមរបស់ព្រះអង្គដែលនឹង______ ______សម្រាប់មនុស្សជាច្រើន______បាប។

៨. ពួកអ្នកខាងគណៈផារិស៊ីបានព័ទ្ធចាប់ព្រះយេស៊ូនៅក្នុងសួនច្បារដែលព្រះអង្គកំពុងអធិស្ឋានហើយបានចាប់ព្រះអង្គយកទៅទៅផ្ទះរបស់______ដែលមានឈ្មោះថាកេផាស។

៩. សម្តេចសង្ឃបានសួរព្រះយេស៊ូ ប្រសិនព្រះអង្គថាព្រះអង្គ______ ព្រះអង្គមានបន្ទូលឆ្លើយថា គឺខ្ញុំហ្នឹងហើយ នៅពេលនោះប្រជាជនបានចូលមកឯព្រះយេស៊ូ និង______ទះព្រះភក្ត្ររបស់ព្រះអង្គ______ព្រះអង្គហើយ និងវាយព្រះអង្គយ៉ាងឃោរឃៅ។

១០.នៅពេលព្រឹកបានមកដល់ ពួកអ្នកខាងគណៈផារិស៊ីបានយកព្រះយេស៊ូទៅអ្នកកាន់អំណាចរ៉ូម៉ាំងឈ្មោះ______។

១១.លោកពីឡាត់មិនបានរកឃើញថា ព្រះយេស៊ូមានទោសនោះទេ ប៉ុន្តែ គាត់បានឱ្យគេឆ្កាងព្រះអង្គដោយព្រោះគាត់ខ្លាច______ក្នុងចំណោមប្រជាជន។

១២.ទាហានរ៉ូម៉ាំងធ្វើទារុណកម្មព្រះយេស៊ូ។ ពួកគេបានដាក់ម្កុដ______នៅលើព្រះសិរព្រះអង្គ ហើយវាយព្រះអង្គ។

១៣.នៅលើឈើឆ្កាងមានផ្លាកមួយដែលនិយាយថា «នេះគឺបុរសឈ្មោះយេស៊ូជា__ ______នៃសាសន៍យូដា»។

១៤.ចាប់ពីម៉ោងទី៦ដល់ម៉ោងទី៩មាន______ជាច្រើននៅលើផែនដី។

មានបុរសអ្នកមានម្នាក់ឈ្មោះយូសែបនៅភូមិអើរីម៉ាថេដែលជាសិស្សរបស់ព្រះយេស៊ូដែរ។ បុរសម្នាក់នេះបានទៅសួរលោកពីឡាត ប្រសិនជាគាត់អាចអនុញ្ញាតឱ្យយកសាកសពរបស់ព្រះយេស៊ូ និងបញ្ចុះព្រះអង្គនៅក្នុងផ្នូរ។ លោកពីឡាតយល់ស្របនឹងសំណើនេះហើយ គាត់បានយកសពរបស់ព្រះយេស៊ូទៅបញ្ចុះទៅក្នុងផ្នូរថ្មីដែលមិនដែលដាក់សពសោះ។ ក្រោយពីបញ្ចុះព្រះសពរបស់ព្រះយេស៊ូហើយ គេបានយកផ្ទាំងថ្មមួយយ៉ាងធំទៅបាំងនៅមាត់ផ្នូរ។

ថ្ងៃបន្ទាប់ពួកអ្នកខាងគណៈផារិស៊ីបានប្រជុំគ្នា និងចូលទៅលោកពីឡាត ពីព្រោះគេនៅចាំព្រះបន្ទូលរបស់ព្រះយេស៊ូថា ព្រះអង្គនឹងរស់ឡើងវិញនៅថ្ងៃទី៣។

ពួកគេសុំលោកពីឡាត ឱ្យមានមនុស្សយាមផ្នូររហូតដល់ថ្ងៃទី៣ ដោយខ្លាចមានគេមកលួចយកព្រះសពរបស់ព្រះយេស៊ូ។ ដូច្នេះលោកពីឡាតអនុញ្ញាតពួកគេទៅយាមផ្នូរ។ ពួកគេបានដេកចាំយាមនៅខាងមុខផ្នូរ ហើយបោះត្រាលើផ្ទាំងថ្មផងដែរ។

នៅថ្ងៃដំបូងនៃសប្ដាហ៍ នាងម៉ារាមកពីស្រុកម៉ាដាឡា និងម៉ារាម្នាក់ទៀតបានមកឯផ្នូរ។ នៅពេលដែលពួកគេមកដល់ផ្នូរ ក៏កើតមានរញ្ជួយដីផ្ទាំងថ្មដែលប្រើសម្រាប់បិទមាត់ផ្នូរបានរបើកឡើង ហើយទេវតានៃព្រះបានអង្គុយនៅលើផ្ទាំងនោះ។ អ្នកយាមដែលនៅការពារនៅទីនោះមានការភ័យខ្លាច ហើយពួកគេបានក្លាយដូចជាមនុស្សស្លាប់។

ទេវតាបាននិយាយទៅកាន់ស្ត្រីទាំងពីរនោះដោយមានបន្ទូលថា «កុំភ័យអីដ្បិតខ្ញុំដឹងហើយថា នាងរកព្រះយេស៊ូដែលត្រូវឆ្កាងតែព្រះអង្គមិនគង់នៅទីនេះទេដ្បិតព្រះអង្គមានព្រះជន្មរស់ឡើងវិញ ហើយដូចជាព្រះអង្គបានមានបន្ទូលទុក ចូរមកមើលកន្លែងដែលព្រះអង្គបានផ្ទំចុះ រួចទៅឱ្យឆាប់ប្រាប់ដល់ពួកសិស្សព្រះអង្គថាព្រះអង្គមានព្រះជន្មរស់ឡើងវិញហើយ។ មើលព្រះអង្គយាងទៅឯស្រុកកាលីឡេមុនអ្នករាល់គ្នាៗនឹងឃើញព្រះអង្គនៅស្រុកនោះ នែខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ»។

ស្ត្រីទាំងពីរនាក់នោះ ក៏ដើរចេញពីផ្នូរជាប្រញាប់ទាំងភ័យ ហើយមានអំណរជាខ្លាំងផង ក៏រត់ទៅប្រាប់ដល់ពួកសិស្សព្រះអង្គ តែកាលដែលនាងកំពុងតែទៅនោះព្រះយេស៊ូបានយាងមកជួបនឹងនាងមានបន្ទូលថា ជំរាបសួរ រួចអ្នកទាំងពីរក៏ចូលទៅឱបព្រះបាទាថ្វាយបង្គំព្រះអង្គ។ នោះព្រះយេស៊ូមានបន្ទូលទៅនាងថា កុំខ្លាចអីចូរទៅប្រាប់បងប្អូនខ្ញុំផង ឱ្យគេទៅស្រុកកាលីឡេទៅគេនឹងឃើញខ្ញុំនៅទីនោះហើយ។

ក្រោយពីព្រះយេស៊ូបានរស់ឡើងវិញ ទាហានដែលបានយាមផ្នូរបានចូលទៅក្នុងក្រុង ហើយប្រាប់សម្ដេចសង្ឃនូវអ្វីដែលបានកើតឡើងនៅឯផ្នូរ។ ពួកសម្ដេចសង្ឃបានពិគ្រោះគ្នា ហើយសម្រេចនឹងឱ្យលុយទៅពួកទាហានជាច្រើនដើម្បីឱ្យពួកគេផ្សព្វផ្សាយដំណឹងជុំវិញទីក្រុងថា ពួកសិស្សបានលួចព្រះសពព្រះយេស៊ូគ្រិស្ដក្នុងពេលដែលពួកគេកំពុងដេកលក់។ ពួកគេថែមទាំងសន្យាដល់ពួកអ្នកយាមថាប្រសិនជារឿងនេះបានឮដល់លោកពីឡាត ពួកគេបានដេកលក់នោះពួកគេនឹងអាចការពារខ្លួនរបស់ពួកគេម្នាក់ៗនៅពីមុខលោកពីឡាតផងដែរ។ ដូច្នេះពួកទាហានបានយកសំណូកនោះ ហើយផ្សាយដំណឹងក្លែងក្លាយនោះជុំវិញទីក្រុងរយៈពេល៣-៤ឆ្នាំ។

ឯពួកសិស្សទាំង១១នាក់នាំគ្នាស្រុកកាលីឡេដល់ភ្នំដែលព្រះយេស៊ូបានប្រាប់ កាលគេឃើញព្រះអង្គនោះក៏ថ្វាយបង្គំតែមានអ្នកខ្លះមានសេចក្ដីសង្ស័យ។

ព្រះយេស៊ូ យាង ចូល មក ជិត គេ ហើយ មាន ព្រះបន្ទូល នឹង គេ ជា ពាក្យ ចុងក្រោយថា « *ខ្ញុំទទួលគ្រប់អំណាចទាំងនៅស្ថានបរមសុខទាំងនៅលើផែនដី។ ដូច្នេះ ចូរ ចេញ ទៅនាំ មនុស្សគ្រប់ជាតិសាសន៍ ឱ្យធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹក ឱ្យគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ត្រូវបង្រៀនគេ ឱ្យប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក*» *អាម៉ែន* ។

## សំនួរផ្ទាល់មាត់

១- តើយ៉ូសែបនៅភូមិអើរីម៉ាថេសុំអ្វីពីលោកពីឡាត់?

២- ហេតុអ្វីបានជាពួកអ្នកខាងគណៈផារិស៊ីខ្លាចនឹងមានអ្វីកើតឡើងចំពោះសពព្រះយេស៊ូនៅថ្ងៃទីបី?

៣- តើអ្នកណាទៅមើលសពព្រះយេស៊ូនៅថ្ងៃដំបូង ហើយតើស្ត្រីទាំងនោះឃើញអ្វីនៅពេលដែលពួកគេទៅដល់ផ្នូរ?

៤- នៅពេលដែលត្រលប់ទៅវិញប្រាប់ពួលសាវ័ក តើពួកគេបានឃើញអ្វី? តើពួកគេចូលទៅអ្នកណា?

៥- ព្រះយេស៊ូបានមានបន្ទូលប្រាប់ពួកសាវ័កថា នឹងជួបពួកគេនៅកន្លែងផ្សេងពីទីក្រុងយេរូសាឡិម។ តើកន្លែងណា?

៦- នៅលើភ្នំ ព្រះយេស៊ូមានបញ្ជាដ៏សំខាន់ដល់សាវ័ករបស់ព្រះអង្គ។ ព្យាយាមបំពេញនៅក្នុងចន្លោះពីព្រះបន្ទូលរបស់ព្រះយេស៊ូ «ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឱ្យមាន________________នៅគ្រប់ទាំងសាសន៍________________ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង________________ចុះ ហើយបង្រៀនគេឱ្យកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើលខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។

## មេរៀនទី៧

# សេចក្តីពិតខាងវិញ្ញាណ

ម៉ាថាយ ២៧-២៨

១- ព្រះយេស៊ូមានព្រះជន្មរស់នៅសព្វថ្ងៃ។ ព្រះយេស៊ូមិនមែនជាមនុស្សធម្មតាដែលអាចចាប់ដាក់គុក និងសម្លាប់បានឡើយ ព្រះអង្គគឺជាព្រះដ៏នៅអស់កល្បជានិច្ច។ ព្រះអង្គគ្មានទីចាប់ផ្តើម ហើយក៏គ្មានទីបញ្ចប់ដែរ ។ គម្រោងការណ៍របស់ព្រះជាម្ចាស់តាំងពីកំណើតពិភពលោក គឺនឹងយាងមកផែនដីក្នុងភាពជាមនុស្ស ធ្វើជាអ្នកបម្រើដើម្បីរងទុក្ខជួសបាបរបស់យើង ។ វាជាបំណងព្រះហឫទ័យរបស់ព្រះអង្គដើម្បីជាប់ឆ្កាងនៅថ្ងៃនោះ និងក្នុងរបៀបយ៉ាងនោះ។ គម្រោងការណ៍របស់ព្រះអង្គមិនអាចនឹងស្ទាក់ស្ទើរបានឡើយ ហើយគ្មានអ្នកណានឹងអាចយកឈ្នះព្រះអង្គបានឡើយ។ ព្រះអង្គគង់នៅ ហើយនៅតែជាព្រះដ៏ពិត និងជាព្រះដែលមានព្រះជន្មរស់។

២- ពួកអ្នកខាងគណៈផារិស៊ីជឿព្រះបន្ទូលរបស់ព្រះយេស៊ូចំណុច ដែលពួកគេបានឱ្យទាហានរបស់ពួកគេយាមផ្នូររបស់ព្រះយេស៊ូក្រោយពីការសោយទិវង្គតរបស់ព្រះអង្គ។ ពីព្រោះព្រះអង្គមានបន្ទូលសន្យាថា ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី។ ពួកគេជឿពាក្យរបស់ពួកទាហាន បានប្រាប់ពួកគេអំពីអ្វីដែលបានកើតឡើង។ ពួកគេថែមទាំងចំណាយលុយឱ្យដល់ពួកទាហានទៅនិយាយកុហកពីការដែលបានកើតឡើងទៀតផង។

អ្នកដឹកនាំទាំងនេះក៏មានវត្តមានផងដែរ នៅពេលដែលលោកយ៉ូហានអ្នកធ្វើពិធីជ្រមុជទឹក ជ្រមុជទឹកឱ្យព្រះយេស៊ូ ហើយសម្លេងរបស់ព្រះជាម្ចាស់ផ្ទាល់ពីស្ថានសួគ៌ប្រាប់ថា ព្រះអង្គជាអ្នកណា។ បុរសទាំងនេះជាសាក្សីនៃការអស្ចារ្យជាច្រើនដែលព្រះអង្គបានធ្វើ ។ ពួកគេថែមទាំងខឹងព្រះអង្គនៅពេលដែលព្រះអង្គប្រោសមនុស្សខ្វិនម្នាក់នៅថ្ងៃឈប់សម្រាកទៀតផង ។ ពួកគេបានឃើញព្រះអង្គដេញអារក្សចេញពីមនុស្សដែលមានអារក្សចូលហើយពួកគេបានមើលឃើញព្រះអង្គលើកលែងទោសដល់មនុស្សផងដែរ។ ស្ទើរតែគ្មានអ្នកណាដឹងពីដំណើរជីវិតរបស់ព្រះយេស៊ូច្រើនជាងពួកមេដឹកនាំសាសនានេះណាស់។ ប៉ុន្តែមនុស្សមួយក្រុមដែលមិន

បានទទួលសេចក្ដីស្រឡាញ់របស់ព្រះដែលព្រះអង្គបានប្រទានដល់ជីវិតរបស់ពួកគេនោះទេ។ ពួកគេមិនបានប្រែចិត្តចេញពីអំពើបាបរបស់ពួកគេនោះទេ។ ពួកគេមិនបាន ចុះចូលនូវជីវិតរបស់ពួកគេនៅក្នុងអំណាចនៃព្រះយេស៊ូគ្រិស្ដទេ។ មានការទំនាក់ទំនងស្និទ្ធស្នាលជាមួយព្រះយេស៊ូ ប្រសើរជាងការរៀននិងជឿលើការពិតនៃជីវិតរបស់ព្រះអង្គទៅទៀត។ វាប្រសើរជាងការជឿសាសនាថ្មី និងសាសនាផ្សេងទៀត ព្រះយេស៊ូមានបំណងចង់ឱ្យយើងប្រែចិត្តពីអំពើបាបរបស់យើង ជឿព្រះអង្គ ហើយប្រគល់ជីវិតរបស់យើងទៅដល់ព្រះអង្គ។ ព្រះអង្គចង់ក្លាយជាព្រះអម្ចាស់ និងជាអ្នកដឹកនាំជីវិតរបស់យើង។ ព្រះអង្គចង់ដឹកនាំជីវិតយើងរាល់ថ្ងៃ។

### ៣- តើព្រះជាយេស៊ូជានរណា?

* ព្រះយេស៊ូប្រសូតពីស្ត្រីព្រហ្មចារី
* ព្រះយេស៊ូអះអាងថាព្រះអង្គជាព្រះ
* ព្រះយេស៊ូធ្វើការអស្ចារ្យជាច្រើន និងអត់ទោសដល់មនុស្សដែលបានប្រែចិត្តចេញពីអំពើបាបរបស់ពួកគេ។
* ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង ដើម្បីសងថ្លៃលោះបាបដែលមាននៅក្នុងជីវិតរបស់យើង ចំពោះព្រះជាម្ចាស់ដ៏សុចរិត។
* ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងមានព្រះជន្មរស់នៅសព្វថ្ងៃ។
* ព្រះយេស៊ូក៏ចង់ឱ្យខ្ញុំប្រែចិត្តចេញពីអំពើបាបរបស់ខ្ញុំផងដែរ និង ប្រ គល់ជីវិតរបស់ខ្ញុំដល់ព្រះអង្គ។

ព្រះគម្ពីរបង្រៀនយើងថា ព្រះយេស៊ូមិនបានសោយទិវង្គត ដើម្បីធ្វើជាគំរូនោះទេ ប៉ុន្តែព្រះអង្គបានសោយទិវង្គតដើម្បីជំនួសលោកអ្នកហើយនិងខ្ញុំ ដែលសក្តិសមប្រឈមមុខនឹងព្រះអម្ចាស់សម្រាប់គ្រប់ការទាំងអស់ដែលយើងបានធ្វើខុសនៅក្នុងជីវិតរបស់យើង។

**ព្រះគម្ពីរបានចែងថា «ដ្បិត អ្នកណាដែលអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងទទួលការសង្គ្រោះ» រ៉ូម ១០:១៣**

* កន្លែងនេះមានន័យថា លះបង់នូងអតីតកាល ខ្ញុំអាចសុំព្រះយេស៊ូមកគង់ក្នុងជីវិតរបស់ខ្ញុំ ហើយព្រះអង្គនឹងអត់ទោសអស់ទាំងអំពើបាបរបស់ខ្ញុំ ហើយព្រះអង្គនឹងរស់នៅក្នុងជីវិតរបស់ខ្ញុំ។
* វាមានន័យថា ក្នុងខណៈពេលដែលព្រះយេស៊ូយាងមកក្នុងចិត្តរបសខ្ញុំ

អំពើបាបពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់ត្រូវបានអត់ទោសឱ្យទាំងអស់ នៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់។ នេះមិនមែនដោយសារតែអ្វីដែលខ្ញុំបានធ្វើនោះទេ។ វាមិនមែនដោយសារតែខ្ញុំបានជ្រើសរើសសាសនាដ៏ល្អនោះទេ។ វាមិនមែនដោយសារតែខ្ញុំមានអត្តចរិតល្អនោះដែរ។ វាមិនមែនដោយសារតែឪពុកម្តាយរបស់ខ្ញុំមកពីពូជអំបូរដែលពិសេស ឬក៏មានឋានៈក្នុងសង្គមដែរ។ គឺដោយសារតែ**មួយគត់** គឺដោយសារតែខ្ញុំបានទទួលនូវយញ្ញបូជាដែលព្រះយេស៊ូបានសងនៅពេលដែលព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង។

* វាមានន័យថា ចាប់ពីពេលនោះមក ខ្ញុំបានក្លាយជាមនុស្សសុចរិតម្តងទៀតនៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់។ ព្រះគម្ពីរបង្រៀនយើងថាឈ្នួលនៃអំពើបាបគឺជាសេចក្តីស្លាប់ ប៉ុន្តែការសោយទិវង្គតរបស់ព្រះយេស៊ូវិញគ្រប់គ្រាន់នឹងឱ្យខ្ញុំបានកើតជាថ្មី ប្រសិនបើខ្ញុំធ្វើការជ្រើសរើសដើម្បីដើរតាមព្រះអង្គនោះ។

ប្រសិនបើជាលោកអ្នកចង់បាននូវការប្រោសលោះរបស់ព្រះជាម្ចាស់ឥឡូវនេះនៅក្នុងជីវិតរបស់លោកអ្នក ហើយនិងចង់ក្លាយជាអ្នកដើរតាមព្រះអង្គ លោកអ្នកអាចនឹងយាងព្រះអង្គឱ្យមកគង់នៅក្នុងជីវិតរបស់លោកអ្នកក្នុងពេលឥឡូវនេះ។

វាមិនមែនចាំបាច់នៅក្នុងសាសនាជាសំខាន់នោះទេ វាក៏មិនចាំបាច់និយាយនូវពាក្យពិសេសៗនោះដែរ។ ការដែលសំខាន់គឺគ្រាន់តែលោកអ្នកចូលមកឯព្រះជាម្ចាស់ ហើយប្រកាសថា លោកអ្នកជឿថា ព្រះយេស៊ូគ្រិស្តជាព្រះ និងចង់ឱ្យព្រះអង្គក្លាយជាព្រះអម្ចាស់ ឬជាអ្នកដឹកនាំជីវិតលោកអ្នកតែប៉ុណ្ណោះ។

**<u>លោកអ្នកអាចអធិស្ឋានដូចខាងក្រោម</u>**

«ឱព្រះវរបិតា! ខ្ញុំដឹងថា ខ្ញុំជាមនុស្សមានបាប។ ខ្ញុំជឿថា ព្រះយេស៊ូបានសោយ-ទិវង្គតនៅលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញដើម្បីសង្គ្រោះខ្ញុំឱ្យរួចពីអំពើបាប។ ខ្ញុំសូមសារភាពនូវអំពើបាបរបស់ខ្ញុំ។ សូមព្រះអង្គយាងមកគង់នៅក្នុងជីវិតរបស់ខ្ញុំ និងលើកលែងទោសដល់ខ្ញុំ ចំពោះគ្រប់ទាំងអំពើបាបទាំងអស់ដែលខ្ញុំបានប្រព្រឹត្ត។ ខ្ញុំសូមប្រគល់ជីវិតរបស់ខ្ញុំដល់ព្រះអង្គ។ ខ្ញុំសូមអរព្រះគុណសម្រាប់សេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះខ្ញុំ។ ខ្ញុំសូមអធិស្ឋានដោយនូវព្រះនាមព្រះយេស៊ូគ្រិស្ត អាម៉ែន។

៤- «ហើយមើល! ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដ៏រាបដល់បំផុតកល្ប»។ ព្រះគម្ពីរយ៉ូហាន ១៤:២ ចែងថា «នៅក្នុងដំណាក់ព្រះបិតារបស់ខ្ញុំ មានទី

លំនៅជាច្រើន ពុំនោះខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា»ព្រះយេស៊ូមានបន្ទូលសន្យាដល់យើងថា គ្រប់គ្នាដែលប្រគល់ជីវិតរបស់គេដល់ព្រះអង្គនឹងរស់នៅអស់កល្បជានិច្ចជាមួយព្រះអង្គក្នុងកន្លែងដែលហៅថា ស្ថានសួគ៌( ស្ថានសួគ៌ គឺជាកន្លែងរបស់ព្រះបិតា ) ថ្ងៃណាដែលយើងបានទទួលព្រះយេស៊ូមកក្នុងជីវិតរបស់យើង យើងនឹងរស់នៅជាមួយនឹងព្រះអង្គអស់កល្បជានិច្ច។ នេះមានន័យថា ព្រះយេស៊ូនឹងគង់នៅជាមួយយើងនៅលើផែនដី ប៉ុន្តែនៅពេលដែលយើងស្លាប់ទៅហើយ យើងនឹងបានទៅរស់នៅជាមួយនឹងព្រះអង្គនៅឯស្ថានសួគ៌អស់កល្បជានិច្ច។

**សេចក្តីស្រឡាញ់ដែលព្រះយេស៊ូមានសម្រាប់យើង គឺមានជារៀងរហូត។**